# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

## សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល

ADVANTAGES OF USING RIEL CURRENCY

## ជំនាញ គណនេយ្យ

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល

# ADVANTAGES OF USING RIEL CURRENCY

គ្រូណែនាំ៖ សួរ កុសល់

ជំនាញ គណនេយ្យ


រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទ៖ អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

សួរ កុសល់

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដាអស់រយៈពេល៤ឆ្នាំសិក្សារួចមកក្រុមនាងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេសក្រុមនាងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិត កាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយរហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្តការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យដើម្បីពង្រឹងប្រសិទ្ធិភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមនាងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ទើបក្រុមនាងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រាក់រៀល។ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណាមួយនេះឡើងនឹងបានចូលរួមចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀត ដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមនាងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



តិចឡុង វីកា



ទុយ គីមឡាង



ណោត វទ្យ



គង់ សុខកែវ

# សេចក្ដីថ្លែងអំណរគុណ

ក្រុមនាងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្ដល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានបណ្ដុះបណ្ដាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្ដមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្ដល់ទីកន្លែងបណ្ដុះបណ្ដាល ព្រមទាំងផ្ដល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **សូរ កុសល់** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្រ្តាចារ្យ លោកគ្រូអ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី "អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល" នេះគឺពិតជាស្នាដៃមួយរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ..៨កើត. ខែ.កត្តិក.. ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី.២៩. ខែ.តុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



តិចឡុង រីកា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ប្រាក់រៀល គឺជារូបិយវត្ថុជាតិកម្ពុជា ដែលមានតួនាទីសំខាន់យ៉ាងខ្លាំងក្នុងការជម្រុញសេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសជាតិ។ ការប្រើប្រាស់ប្រាក់រៀលជារូបិយវត្ថុក្នុងប្រទេសមួយគឺជា ចំណុចសំខាន់មួយ ដែលជួយលើកកម្ពស់សមិទ្ធផលសេដ្ឋកិច្ច ជំរុញឱ្យមានភាពឯករាជ្យផ្នែកហិរញ្ញវត្ថុ និង ការរីកចម្រើនក្នុងវិស័យជាតិជាចម្បង។ គ្រប់បណ្តាពាណិជ្ជកម្ម មិនថាសហគ្រាសខ្នាតតូច មធ្យម និងធំ សុទ្ធតែត្រូវការរូបិយវត្ថុដើម្បីធ្វើជាទុនចម្បងក្នុងការបង្កើតអាជីវកម្ម និងសហគ្រាស។ ម្យ៉ាងវិញទៀតរូបិយវត្ថុជាតិដើរតួនាទីយ៉ាងនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ។ ដើម្បីឱ្យរូបិយវត្ថុជាតិនៅក្នុងប្រទេសយើងដើរ ធនាគារជាតិនៃកម្ពុជាគួរតែអនុវត្តន៍ រាល់ជំនួយ និងការវិនិយោគពីបរទេស គួរធ្វើការប្តូរប្រាក់ទៅជាប្រាក់រៀល ដើម្បីឱ្យអាជ្ញាធររូបិយវត្ថុអាចមានលទ្ធភាពក្នុងការស្រូបយករូបិយប័ណ្ណបរទេសចូលទៅក្នុងប្រព័ន្ធធនាគារនិងបញ្ចេញរូបិយវត្ថុជាតិចូលទៅក្នុងសេដ្ឋកិច្ចកាន់តែច្រើន។

មួយចំនួននៃអត្ថប្រយោជន៍សំខាន់ៗនៃការប្រើប្រាស់ប្រាក់រៀលមានដូចជា៖ ដំបូងបង្អស់ វាជួយកាត់បន្ថយការពឹងផ្អែកលើរូបិយបណ្ណបរទេស ដែលអាចបណ្តាលឱ្យមានភាពអស្ថិរភាពនៃអត្រាប្តូរប្រាក់ និងការជួញដូរពាក់ព័ន្ធ។ បន្តទៀតវាជួយអោយគណៈបញ្ជាការប្រាក់មានអំណាចក្នុងការគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចបានប្រសើរឡើង ពិសេសក្នុងការគ្រប់គ្រងអត្រាប្តូរប្រាក់ និង ការបោះក្រដាសប្រាក់ប្រកបដោយការសុវត្ថិភាពសេដ្ឋកិច្ចជាតិ។ វានិងជួយបង្កើនភាពទុកចិត្តលើរូបិយវត្ថុជាតិ និងលើប្រព័ន្ធហិរញ្ញវត្ថុជាតិកាន់តែខ្ពស់។ ក្រៅពីនេះ ការប្រើប្រាស់ប្រាក់រៀលក៏ជាផ្នែកនៃការលើកស្ទួយអត្តសញ្ញាណជាតិ និងស្មារតីស្រលាញ់ជាតិផងដែរ។ ពលរដ្ឋដែលប្រើប្រាស់ប្រាក់រៀលជាប្រចាំ គឺកំពុងចូលរួមដ៏សំខាន់ក្នុងការជួយសេដ្ឋកិច្ចក្នុងស្រុក ដោយលើកស្ទួយអាជីវកម្មក្នុងស្រុក និងការប្រើប្រាស់សេវាកម្មនានាដែលផ្តល់ផលជាសុទ្ធសាធទៅឱ្យប្រទេសជាតិ។

ដោយសារៈសំខាន់នៃប្រាក់រៀលក្នុងវិស័យសេដ្ឋកិច្ច ជាពិសេសមិនថាគ្រប់ស្ថាប័នរដ្ឋ និងស្ថាប័នឯកជនត្រូវតែបើកប្រាក់បៀវត្សឱ្យនិយោជិតជារូបិយវត្ថុជាតិ។ បន្ថែមពីនេះគ្រប់ស្ថាប័នធនាគារ ត្រូវតែចូលរួមផ្សព្វផ្សាយអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀលឱ្យបានច្រើន។ ប្រជាជនខ្មែរយើងត្រូវតែរួមគ្នាសហការ និងជួយលើកតម្កើងរូបិយជាតិគ្រប់សម័យកាល។ គ្រប់ស្ថាប័ន និងពលរដ្ឋគួររៀបចំយុទ្ធនាការជំរុញឱ្យប្រើប្រាស់ប្រាក់រៀលយ៉ាងទូលំទូលាយ ដើម្បីជំរុញសេដ្ឋកិច្ចឱ្យរីកចម្រើន និងបន្តការអភិវឌ្ឍប្រទេសយើងឱ្យកាន់តែរឹងមាំនៅពេលអនាគត។

# មាតិកា


ទំព័រ

អារម្ភកថា ........ i

រចនាសម្ព័នក្រុម ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

មាតិកា ........ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៤.១ ទំហំដែនកំណត់ ........ ២

១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

១.៦.១ចំពោះសមាជិកក្រុមអ្នកស្រាវជ្រាវផ្ទាល់ ........ ៣

១.៦.២ ចំពោះធនាគារជាតិ ........ ៣

១.៦.៣ ចំពោះសង្គម និង សេដ្ឋកិច្ចជាតិ ........ ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី២
## រំលឹកទ្រឹស្តី

២.១ លក្ខណៈទូទៅនៃរូបិយវត្ថុ ........ ៦

២.១.១ និយមន័យរូបិយវត្ថុ ........ ៦

២.១.២ ប្រវត្តិនៃរូបិយវត្ថុ ........ ៦

២.១.៣ ប្រភេទនៃរូបិយវត្ថុ ........ ៧

២.១.៤ សារៈសំខាន់នៃរូបិយវត្ថុ ........ ៨

២.២ នីតិវិធីក្នុងការគ្រប់គ្រងប្រាក់រៀលរបស់ធនាគារជាតិ ........ ៩

២.២.១ និយមន័យនីតិ ........ ៩

២.២.២ ប្រវត្តិនីតិ............................................................................................................១០
២.២.៣ ទ្រឹស្តីនីតិ ..........................................................................................................១១
២.៣ ការប្រើប្រាស់ប្រាក់រៀលជួយលើកស្ទួយដល់សេដ្ឋកិច្ចជាតិ ............................................................ ១២
២.៣.១ និយមន័យសេដ្ឋកិច្ច ........................................................................................... ១២
២.៣.២ ប្រវត្តិនៃសេដ្ឋកិច្ច.............................................................................................. ១២
២.៣.៣ ទ្រឹស្តីនៃសេដ្ឋកិច្ច.............................................................................................. ១៣

## ជំពូកទី៣

## លទ្ធផលនៃការស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅរបស់ធនាគារជាតិនៃកម្ពុជា ......................................................................១៥
៣.១.១ ប្រវត្តិនៃការកកើត និងការអភិវឌ្ឍន៍របស់ធនាគារជាតិនៃកម្ពុជា ...........................១៥
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់ធនាគារជាតិនៃកម្ពុជា ...............................១៩
ក.ចក្ខុវិស័យ ...........................................................................................................១៩
ខ. បេសកកម្ម..........................................................................................................១៩
គ. គោលដៅ ...........................................................................................................១៩
៣.១.៣ រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា ............................................................. ២១
៣.២ នីតិវិធីក្នុងការប្រើប្រាស់ប្រាក់រៀលឱ្យមានប្រសិទ្ធភាពរបស់ធនាគារជាតិនៃកម្ពុជា .................២២
៣.២.១ គោលនយោបាយអត្រាប្តូរប្រាក់ ...........................................................................២២
៣.២.២ គោលនយោបាយប្រាក់បម្រុងកាតព្វកិច្ច...............................................................២២
៣.២.៣ ការគ្រប់គ្រងការផ្គត់ផ្គង់សាច់ប្រាក់.......................................................................២២
៣.២.៤ កាត់បន្ថយចំណាយប្រតិបត្តិការ............................................................................២៣
៣.២.៥ រក្សាស្ថិរភាពថ្លៃ.................................................................................................២៣
៣.២.៦ ជំរុញពាណិជ្ជកម្ម................................................................................................ ២៤
៣.២.៧ ជំរុញការវិនិយោគ និងការបង្កើតការងារ ................................................................ ២៤
៣.២.៨ បង្ការការក្លែងក្រដាសប្រាក់.................................................................................. ២៥
៣.៣. ការប្រើប្រាស់ប្រាក់រៀលជួយលើកស្ទួយដល់សេដ្ឋកិច្ចជាតិ ........................................................ ២៥
៣.៣.១ មោទនភាព និងសាមគ្គីភាពជាតិ ........................................................................ ២៥
៣.៣.២ គោលនយោបាយសារពើពន្ធ ............................................................................... ២៥
៣.៣.៣ គោលនយោបាយពាណិជ្ជកម្ម................................................................................ ២៦
៣.៣.៤ គោលនយោបាយអភិវឌ្ឍន៍ទីផ្សារ.......................................................................... ២៨
៣.៣.៥ ការលើកកម្ពស់ការយល់ដឹង និងការចូលរួម........................................................... ២៩
៣.៣.៦ គោលនយោបាយគាំទ្រ........................................................................................ ៣០

## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង....................................................................................៣១
៤.២ ការវិភាគលើចំណុចខ្សោយ .................................................................................. ៣២

## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ............................................................................................ ៣៣
៥.២ ការផ្តល់អនុសាសន៍ ..........................................................................................៣៤
**ឯកសារយោង**
**ឧបសម្ព័ន**

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

គ្រប់ជាតិសាសន៍លើពិភពលោក សុទ្ធតែត្រូវការពាណិជ្ជកម្មនាំចេញ នាំចូល។ ការនាំចេញ ចូលទំនិញចរាចរណ៍ទាំងនេះ ត្រូវការជាដាច់ខាតនូវវត្ថុដែលជាអាជ្ញាកណ្តាលមួយ ដែលត្រូវបានគេស្គាល់ថាជាលុយ។ លុយ ឬរូបិយប័ណ្ណមានតម្លៃធំធេងណាស់ក្នុងសេដ្ឋកិច្ចនៃប្រទេសមួយ ដែលយើងមិនអាចមើលរំលងបានឡើយ។ គ្រប់ប្រទេសទាំងឡាយ តែងមានរូបិយប័ណ្ណដែលជាតំណាងរបស់ខ្លួនផ្ទាល់ គ្រាន់តែតម្លៃរបស់ វានីមួយៗប្រែប្រួលទៅតាមការវិវត្តន៍របស់ពិភពលោកខាងក្រៅប៉ុណ្ណោះ។ការប្រើប្រាស់ប្រាក់រៀលបានផ្តល់នូវអត្ថប្រយោជន៍ច្រើនដល់ប្រជាពលរដ្ឋខ្មែរដែលសម្បូរចំណុចអាចកត់សំគាល់បានដូចជា ការរក្សាការរីកចម្រើនសេដ្ឋកិច្ចក្នុងស្រុក ការបង្កើនការជឿជាក់លើស្តង់ដារហិរញ្ញវត្ថុជាតិ និងការធានាស្ថេរភាពសាច់ប្រាក់ជាតិ។ ជាពិសេស ការប្រើប្រាស់ប្រាក់រៀលអាចជួយកាត់បន្ថយការពឹងផ្អែកលើរូបិយប័ណ្ណបរទេសនិងការបណ្តាលឱ្យមានសមភាពក្នុងការចំណាយរបស់សហគមន៍ជាតិ។

សេដ្ឋកិច្ចនៃប្រទេសមួយត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រតិបត្តិការនៃរូបិយប័ណ្ណរបស់ខ្លួន។ តើមានប្រទេសណាមួយដែលមិនចាយលុយផ្ទាល់ខ្លួននោះ? មានប្រទេសខ្លះបានបានបង្កើតសហភាពខ្លួន ដូចជា នៅអឺរ៉ុប ដើម្បីធ្វើឱ្យអំណាចនៃរូបិយប័ណ្ណរបស់ខ្លួនរឹងមាំ ដូចជា ការប្រើប្រាស់រូបិយប័ណ្ណតែមួយ (ប្រាក់ អឺរ៉ូ) និង ដើម្បីពង្រឹងអំណាចសេដ្ឋកិច្ចរបស់ខ្លួន។ ហេតុនេះហើយបានជាតម្លៃប្រាក់អឺរ៉ូ មានតម្លៃ ថ្លៃជាងប្រាក់ដុល្លារ របស់អាមេរិក។ យ៉ាងណាក៏ដោយការប្រើប្រាស់ប្រាក់ដុល្លារ មានស្ទើរតែគ្រប់ប្រទេសលើសកលលោក ដោយគេចាត់ទុកថា វាជារូបិយប័ណ្ណអន្តរជាតិមួយក្នុងការធ្វើសេដ្ឋកិច្ចនានា។វត្តមាននៃប្រាក់ដុល្លារផ្តល់ទាំងផលវិជ្ជមាន និង អវិជ្ជមាន។ ហេតុដូចនេះហើយទើបយុទ្ធសាស្ត្រនៃការប្រើប្រាស់ប្រាក់រៀលបានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាបានអនុវត្តន៍គោលនយោបាយរូបិយវត្ថុរបស់ខ្លួនឱ្យបានល្អប្រសើរជាងមុន ដោយសារតែរូបិយវត្ថុជាតិមានសារៈសំខាន់ ។

ការចាយវាយលុយកាក់ជាអ្វីដែលត្រូវធ្វើជាប្រចាំមិនថាបុគ្គលនោះក្រ ឬ មាននោះឡើយខុសតែគម្លាតនៃការចាយវាយប៉ុណ្ណោះ។ លុយ ឬប្រាក់ដែលត្រូវចំណាយ គឺជាសរសៃឈាមមួយនៃជីវិតរបស់មនុស្ស។ តើមានអ្នកណាដែលថាមិនចាយលុយនៅសម័យនេះ? ជាតិសាសន៍ទាំងឡាយរមែងមានរូបិយវត្ថុផ្ទាល់ខ្លួនមួយជាតំណាង និង ដើម្បីធ្វើឱ្យសេដ្ឋកិច្ចខ្លួនមានដំណើរការ។ ការសិក្សាស្វែងយល់អំពីរូបិយវត្ថុជាតិ និងអន្តរជាតិពិតជាមានសារៈសំខាន់ណាស់។ប្រធានបទយើងនៅពេលនេះ គឺផ្តោតជាសំខាន់ទៅ លើការប្រើប្រាស់ប្រាក់រៀល និង ការវិវត្តន៍ផ្សេងៗដែលទាក់ទងនឹងប្រាក់រៀលខ្មែរ និងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា។ ហេតុនេះហើយបានជាក្រុមនាងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទ «អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល» យកមកធ្វើការស្រាវជ្រាវ ក្នុងគោលបំណងស្វែងយល់អំពីស្ថានភាពទូទៅ និងការប្រើប្រាស់រូបិយវត្ថុជាតិឱ្យកាន់តែមានកំណើននៅក្នុងសេដ្ឋកិច្ចជាតិ និងចងក្រងទុកជាឯកសារដែលមានប្រយោជន៍ដល់និស្សិតជំនាន់ក្រោយៗ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឱ្យជ្រាបជាព័ត៌មានកាន់តែច្បាស់អំពី អត្ថប្រយោជន៍ជាច្រើននៃការប្រើប្រាស់ប្រាក់រៀលចំពោះសេដ្ឋកិច្ចកម្ពុជា ក្រុមនាងខ្ញុំបានលើកជាចំណុច និងសំណួរដែលពាក់ព័ន្ធទៅនឹងប្រធានបទដូចខាងក្រោម៖

១. តើធនាគារជាតិមាននីតិវិធីដូចម្តេចខ្លះក្នុងការប្រើប្រាស់ប្រាក់រៀលឱ្យមានប្រសិទ្ធភាព?

២. តើការប្រើប្រាស់ប្រាក់រៀលជួយលើកស្ទួយអ្វីខ្លះដល់សេដ្ឋកិច្ចជាតិ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់នៅក្នុងការស្រាវជ្រាវលើប្រធានបទ គឺចង់ពង្រឹងឱ្យកាន់តែច្បាស់នូវការយល់ដឹងពីនីតិវិធីក្នុងការប្រើប្រាស់ប្រាក់រៀលឱ្យមានប្រសិទ្ធភាព និង ការប្រើប្រាស់ប្រាក់រៀលជួយលើកស្ទួយដល់សេដ្ឋកិច្ចជាតិ។ ដោយផ្តោតលើការសិក្សាពីចំណុចៗមួយចំនួនដូចជា ៖

- ស្ថានភាពទូទៅរបស់ធនាគារជាតិនៃកម្ពុជា
- ប្រវត្តិ និងស្ថានភាពរូបិយវត្ថុនៅកម្ពុជា
- ស្វែងយល់ពី ចក្ខុវិស័យ បេសកកម្ម និង គោលដៅ របស់ធនាគារជាតិនៃកម្ពុជា
- យល់ដឹងបន្ថែមពីនីតិវិធីក្នុងការប្រើប្រាស់ប្រាក់រៀលឱ្យមានប្រសិទ្ធភាព
- យល់ដឹងបន្ថែមពីការប្រើប្រាស់ប្រាក់រៀលជួយលើកស្ទួយដល់សេដ្ឋកិច្ចជាតិ
- ប្រសិទ្ធភាពនៃការប្រើប្រាស់ប្រាក់រៀលកន្លងមក និងពេលបច្ចុប្បន្ន
- ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ
- ដើម្បីទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយៗធ្វើការសិក្សាស្វែងយល់បន្ថែមពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ ដែនកំណត់

ដើម្បីឱ្យកិច្ចការស្រាវជ្រាវពីប្រធានបទ អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល មួយនេះអោយមានភាពច្បាស់លាស់ ក្រុមនាងខ្ញុំបានសម្រេចសិក្សា និងធ្វើការស្រាវជ្រាវផ្តោតសំខាន់ទៅលើទិន្នន័យនិងព័ត៌មានចម្បងនានារបស់ធនាគារជាតិនៃកម្ពុជា ហើយធ្វើការវិភាគទៅលើរបាយការណ៍ផ្សេងៗដែលបានធ្វើឡើងសម្រាប់ប្រធានបទនេះតែប៉ុណ្ណោះ។ ការលើកយកធនាគារជាតិនៃកម្ពុជាដើម្បីទុកធ្វើជាភស្តុតាងក្នុងការបកស្រាយពីប្រធានបទអោយបានកាន់តែស៊ីជម្រៅ ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ដោយសារតែពេលវេលានៃការស្រាវជ្រាវពីប្រធានបទខាងលើនេះមានកំណត់ដូច្នេះទើបក្រុមនាងខ្ញុំសម្រេចកំណត់យកឯកសារ និងទិន្នន័យពាក់ព័ន្ធនានាដែលផ្តោតទៅលើអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀលនៅក្នុងចន្លោះឆ្នាំ២០២២ ដល់ ២០២៣ ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវបានប្រើប្រាស់តាមវិធីសាស្ត្រគុណវិស័យដោយផ្តោតចម្បងទៅលើការវិភាគទិន្នន័យនិងឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់

អំពីការប្រើប្រាស់ប្រាក់រៀលជួយលើកស្ទួយដល់សេដ្ឋកិច្ចជាតិ និងការប្រើប្រាស់ប្រាក់រៀលផ្តល់សារៈសំខាន់ដល់សេដ្ឋកិច្ច។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជាការវិភាគលើប្រធានបទទាំងមូល កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ (www.nbc.com.kh) និង Facebook Page របស់ធនាគារជាតិនៃកម្ពុជាផ្ទាល់ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវ ឯកសារមេរៀនទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ របាយការណ៍និងទន្និន័យចាស់ៗ ដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជាវិភាគលើប្រធានបទទាំងមូល កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ (www.nbc.com.kh) និង Facebook Page របស់ធនាគារជាតិនៃកម្ពុជាផ្ទាល់ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវ ឯកសារមេរៀនទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ របាយការណ៍និងទន្និន័យចាស់ៗ ដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះពិតជាផ្តល់សារៈសំខាន់និងអត្ថប្រយោជន៍ជាច្រើនជាពិសេសចំពោះ៖

### ១.៦.១ ចំពោះសមាជិកក្រុមអ្នកស្រាវជ្រាវផ្ទាល់

- យល់ដឹងបន្ថែមអំពីព័ត៌មានថ្មីៗដែលទាក់ទងទៅនឹងអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល
- ចេះធ្វើការងារជាក្រុម និង មានទំនួលខុសត្រូវលើកិច្ចការស្រាវជ្រាវ
- ទទួលបានចំណេះដឹងបន្ថែម និងបទពិសោធន៍ថ្មីៗក្នុងការស្រាវជ្រាវពីសំណាក់គ្រូដឹកនាំ
- ពង្រឹងសមត្ថភាពនៅក្នុងការសរសេររបាយការណ៍
- យល់ដឹងកាន់តែស៊ីជម្រៅ ព្រមទាំងអាចសម្រេចចិត្តមិនងាយស្តាយក្រោយ
- បានផ្តល់ជាឯកសារដល់និស្សិតជំនាន់ក្រោយៗសម្រាប់ជាគំរូក្នុងការធ្វើកិច្ចការស្រាវជ្រាវ ។

### ១.៦.២ ចំពោះធនាគារជាតិ

- ជួយធនាគារជាតិផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល ដើម្បីឱ្យប្រជាជនខ្មែរងាកមកនិយមប្រើប្រាស់រូបិយវត្ថុជាតិវិញ។
- ជួយបង្កើនប្រសិទ្ធភាពការងារធនាគារជាតិក្នុងការពង្រឹងសេដ្ឋកិច្ច ឱ្យកាន់តែរឹងមាំប្រកបដោយចីរភាពនៅនាពេលអនាគត។

### ១.៦.៣ ចំពោះសង្គម និងសេដ្ឋកិច្ចជាតិ

- បានផ្សព្វផ្សាយពីចំណេះដឹងទៅដល់និស្សិតជំនាន់ក្រោយ ឱ្យយល់ដឹងពីការអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល ចំពោះសង្គម និងសេដ្ឋកិច្ច។
- ដើម្បីទុកជាឯកសារដល់និស្សិតជំនាន់ក្រោយដើម្បីធ្វើការសិក្សាស្រាវជាវបន្តទៀតដើម្បីទទួលបានចំណេះដឹងបន្ថែមទៀត។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ធ្វើឡើងដើម្បីស្វែងយល់ឱ្យដឹងកាន់តែច្បាស់នូវចំណុចនីមួយៗ និងការរាប់បញ្ចូលចំណុចដែលមានសេចក្តីផ្តើមនៃការស្រាវជ្រាវ គោលបំណងវិធីសាស្ត្រ សារៈសំខាន់នៃ ការស្រាវជ្រាវ រចនាសម្ព័ន្ធនៃ ការស្រាវជ្រាវ សេចក្តីសន្និដ្ឋាន អនុសាសន៍ និងមានចំណុចជាច្រើនទៀត។ ក្រោយពីបានសិក្សាស្រាវជ្រាវរួចមក ក្រុមនាងខ្ញុំ ក៏បានបែងចែកជាប្រាំជំពូកដែលបានរៀបរាប់ដូចខាងក្រោម៖

**ជំពូកទី១៖ សេចក្តីផ្តើម** ការបរិយាយពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃ ការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាព វិធីសាស្ត្រនៃ ការស្រាវជ្រាវ សារៈសំខាន់នៃ ការស្រាវជ្រាវ។

**ជំពូកទី២៖ រំលឹកទ្រឹស្តី** ការបង្ហាញពីនិយមន័យ ប្រវត្តិទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីអ្នកប្រាជ្ញដែលពាក់ព័ន្ធនឹងការស្រាវជ្រាវ។

**ជំពូកទី៣៖ លទ្ធផលនៃការស្រាវជ្រាវ** ការបង្ហាញស្ថានភាពទូទៅរបស់ធនាគារ ប្រវត្តិធនាគារ ចក្ខុវិស័យ បេសកកម្ម គោលដៅ រចនាសម្ព័ន្ធចាត់តាំង តួនាទី និងភារកិច្ចអ្នកគ្រប់គ្រង នីតិវិធីនៃ ការគ្រប់គ្រងសាច់ប្រាក់ នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយ និងសារៈសំខាន់នៃការគ្រប់គ្រងសាច់ប្រាក់។

**ជំពូកទី៤៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ** ស្វែងយល់ពីចំណុចខ្លាំង និងខ្សោយរបស់ប្រធានបទដែលពាក់ព័ន្ធនឹងប្រធានបទ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** សន្និដ្ឋានទៅលើគ្រប់ចំណុចដែលមានក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចខ្សោយ ដើម្បីកែលម្អ។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២
# អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល

## ២.១ លក្ខណៈទូទៅនៃរូបិយវត្ថុ

### ២.១.១ និយមន័យរូបិយវត្ថុ

**រូបិយវត្ថុ** គឺជាអ្វីៗដែលត្រូវបានគេទទួលស្គាល់ជាទូទៅ និងត្រូវបានគេប្រើប្រាស់ដោយផ្ទាល់នៅក្នុងការទិញទំនិញ ឬសេវានានា ដែលជាទូទៅមាននៅក្នុងដៃភ្នាក់ងារសេដ្ឋកិច្ច (រដ្ឋាភិបាល ក្រុមហ៊ុនអាជីវកម្ម និងក្រុមគ្រួសារ)[1]។

**រូបិយវត្ថុ** គឺជាមធ្យោបាយនៃការចាយវាយទូទាត់បំណុលដែលត្រូវបានគេទទួលស្គាល់ជាសកល និងមាននៅក្នុងដៃអ្នកសេដ្ឋកិច្ចទៀត[2]។

**រូបិយវត្ថុ** គឺវត្ថុណាមួយដែលត្រូវគេទទួលស្គាល់ជាទូទៅថា សម្រាប់ចំណាយលើទំនិញ និងសេវាកម្ម និងទូទាត់បំណុលក្នុងប្រទេសណាមួយ ឬក្នុងបរិបទសង្គមសេដ្ឋកិច្ចណាមួយ[3]។

### ២.១.២ ប្រវត្តិនៃរូបិយវត្ថុ

រូបិយវត្ថុដែលបានប្រើប្រាស់នៅលើពិភពលោករហូតដល់សព្វថ្ងៃនេះ មានប្រវត្តិវែងឆ្ងាយណាស់មកហើយ ដោយផ្អែកទៅលើឯកសារប្រទេសអង់គ្លេសដែលបានផ្សព្វផ្សាយជុំវិញពិភពលោក។ ប្រទេសក្រិចបានប្រើប្រាស់លុយលោហៈធាតុមុនគេបង្អស់កាលពីសតវត្សទី១៧នាក្រុងលីឌី និងបន្ទាប់មកចក្រភពអង់គ្លេសដែលបានណែនាំការប្រើប្រាស់លុយជាផ្លូវការដោយមានការទទួលស្គាល់ពីធនាគារអង់គ្លេស (The Bank of England) រហូតមកដល់ពេលនេះធនាគារនេះមានអាយុជាង២០០ឆ្នាំមកហើយ។ លោកអាដាម ស្មីត (Adam Smith, 1723-1790) ជាសេដ្ឋវិទូអង់គ្លេសដ៏ល្បីល្បាញបានណែនាំពីអត្ថប្រយោជន៍នៃការប្រើប្រាស់រូបិយវត្ថុតាំងពីមុនការបើកធនាគារទៅទៀត។ ជាការរំលឹកគុណដល់លោក ធនាគារអង់គ្លេសបានយករូបលោកដាក់នៅក្នុងប្រាក់កាក់១ផោន។

នៅក្នុងប្រវត្តិសាស្ត្រ ប្រទេសកម្ពុជាត្រូវបានប្រើប្រាស់រូបិយវត្ថុតាំងពីសម័យនគរភ្នំសតវត្សទី១នៃគ្រឹះសករាជ ដោយសារការជីករកឃើញនៅតំបន់ភ្នំដិន ខេត្តតាកែវ របស់ក្រុមភូមិសាស្ត្របុរាណវិទូ និងស្របគ្នាទៅនឹងការរកឃើញរបស់បារាំងនៅកំពង់ផែអូកែវ ខេត្តអានយ៉ាង ទឹកដីកម្ពុជាក្រោម។ សម័យកាលនោះគេប្រើរូបិយវត្ថុបីប្រភេទ គឺតំបន់កណ្តាលប្រើប្រាស់រូបិយវត្ថុរៀល តំបន់ខាងជើងប្រើប្រាស់រូបិយវត្ថុត្រណោត និងតំបន់ក្រោមប្រើប្រាស់រូបិយវត្ថុស្លឹង។

---

[1] វិទ្យាស្ថាន វ៉ាន់ដា. (ឆ្នាំ២០២៤). *“រូបិយវត្ថុ និងធនាគារ(ភាគទី១)”* បោះពុម្ពលើកទី៦. ទំព័រទី២. ភ្នំពេញ

[2] វិទ្យាស្ថាន វ៉ាន់ដា. (ឆ្នាំ២០២៤). *“រូបិយវត្ថុ និងធនាគារ(ភាគទី១)”* បោះពុម្ពលើកទី៦. ទំព័រទី៦. ភ្នំពេញ

[3] KHsearch. សេដ្ឋកិច្ច. (2020, January 05). *និយមន័យរូបិយវត្ថុ*. Retrieved from https://www.khsearch.com/qna/27205

នៅក្នុងសតវត្សទី១នៃគ្រឹះសករាជរហូតសម័យអង្គរ ព្រះរាជាណាចក្រខ្មែរប្រើរូបិយវត្ថុដែលមានរាង ជាស្នូកជ្រូក រាងចតុកោណស្មើ រហូតដល់រាងដូចមាស ប្រាក់សន្លឹកនាពេលបច្ចុប្បន្នកាលនេះបើយោងទៅ លើភស្តុតាងប្រវត្តិសាស្ត្រដែលរកឃើញដោយក្រុមអ្នកភូមិសាស្ត្រកម្ពុជា កាលសម័យអាណានិគមបារាំងដែលរកឃើញនៅម្ទូរព្រៃ និងតាមការសិក្សារបស់អ្នកស្រី ត្រឹងងាសាស្ត្រាចារ្យប្រវត្តិសាស្ត្រកម្ពុជាដែលសរសេរ កាលពីសម័យសង្គមរាស្ត្រនិយម។ នៅលើមាសសន្លឹក គឺបានប្រថាប់ត្រាសម្គាល់នូវទំហំសាច់ប្រាក់ទៅតាមទម្ងន់ និងផ្ទៃរបស់វា។

ក្រោយពីទទួលបានឯករាជ្យពីបារាំង នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ កម្ពុជាបានបង្កើតធនាគារ ជាតិនៃកម្ពុជា នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥៤ និងបានបោះផ្សាយប្រាក់រៀលលើកដំបូង នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៥។ ប៉ុន្តែគួរឱ្យសោកស្ដាយរបបប្រល័យពូជសាសន៍ប៉ុលពតបានចូលមកដល់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ បានកាប់សម្លាប់ប្រជាជនស្លូតត្រង់ បានបំផ្លាញចោលអ្វីៗទាំងអស់រួមទាំងប្រព័ន្ធរូបិយវត្ថុ និងហិរញ្ញវត្ថុ ពោលគឺបានលុបបំបាត់លុយកាក់ ឬកម្មសិទ្ធិស្របច្បាប់ផ្សេងៗទៀត ដែលជាកម្លាំងញើសឈាមរបស់ប្រជាជនកម្ពុជាចោលអស់តែក្នុងរយៈពេលមួយថ្ងៃ។

ក្រោយពីរួចផុតពីសម័យខ្មែរក្រហម នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានបន្ថែមងារជាឈ្មោះធនាគារជាតិនៃកម្ពុជាទៅជាធនាគារកណ្ដាល ឬធនាគារជាតិនៃប្រជាជនកម្ពុជា សម្រាប់គ្រប់គ្រងទៅស្ថាប័នហិរញ្ញវត្ថុ រហូតមកដល់សព្វថ្ងៃ។ ធនាគារជាតិនៃកម្ពុជា ឬធនាគារកណ្ដាល បានបោះរូបិយវត្ថុជាតិ "រៀល" លើកទី២ ឡើងវិញនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ដើម្បីរួមចំណែកអភិវឌ្ឍន៍ជាតិមាតុភូមិ និងបង្ហាញពីអធិបតេយ្យភាពជាតិខ្មែរនៅលើឆាកអន្តរជាតិ[4]។

**២.១.៣ ប្រភេទនៃរូបិយវត្ថុ**

រូបិយវត្ថុសរុប គឺជាការប្រមូលផ្តុំទ្រព្យសម្បត្តិហិរញ្ញវត្ថុ ដោយយោងទៅលើកម្រិតសាច់ប្រាក់ទំនេរទាំងអស់ដែលគេប្រើសម្រាប់ការវាស់វែងរូបិយវត្ថុ។ មូលដ្ឋានរូបិយវត្ថុនាពេលបច្ចុប្បន្នមាន M1 M2 និងM3។

នាពេលបច្ចុប្បន្នការផ្ទេរយ៉ាងងាយស្រួល ពីទ្រព្យសម្បត្តិមកជារូបិយវត្ថុតាមរយៈប្រព័ន្ធអេឡិចត្រូនិកធនាគារដែលជាហេតុធ្វើឱ្យរូបិយវត្ថុរបស់ធនាគារត្រូវរាប់បញ្ចូលទ្រព្យសម្បត្តិនានា ដែលធ្វើបញ្ញើធនាគារ ដែលទីបំផុតធនាគារត្រូវតែគិតអំពីការផ្លាស់ប្តូរនយោបាយរូបិយវត្ថុផងដែរ។ ខាងក្រោមនេះជាសេចក្តីបញ្ជាក់ការវាស់វែងជាផ្លូវការនៃរូបិយវត្ថុៈ

- រូបិយវត្ថុM1 ៖គឺជារូបិយវត្ថុទាំងឡាយណា ដែលងាយស្រួលធ្វើការទូទាត់ ឬចាយវាយបានភ្លាមៗ។ រូបិយវត្ថុរួមមានៈប្រាក់កាក់ ក្រដាសប្រាក់នៅក្រៅធនាគារមូលប្បទានបត្ររបស់អ្នកទេសចរណ៍ព្រមទាំងប្រាក់បញ្ញើចរន្តនៅក្នុងធនាគារ និងស្ថាប័នបញ្ញើផ្សេងៗទៀត។
- រូបិយវត្ថុM2 ៖ ទោះបីជាM1កំពុងតែត្រូវបានមើលឃើញយ៉ាងកៀកបំផុតនូវតួលេខរូបិយវត្ថុក៏ឃើញមាននូវអង្គផ្សំ ផ្សេងៗទៀតដែលធ្វើឱ្យមានការចាប់អារម្មណ៍ពីពេលមួយទៅពេលមួយទៀត។

[4] វិទ្យាស្ថាន វ៉ាន់ដា. (ឆ្នាំ២០២៤). *រូបិយវត្ថុ និងធនាគារ(ភាគទី១)*. បោះពុម្ពលើកទី៦. ទំព័រទី២-៦. ភ្នំពេញ

M2 គឺជារូបិយវត្ថុទ្រព្យសកម្ម (Assets Money) ឬមានលក្ខណៈ ជិតក្បែរនឹងរូបិយវត្ថុ (Near money) រួមមាន៖ M1ព្រមទាំងទ្រព្យសកម្ម ផ្សេងទៀត ។

- រូបិយវត្ថុ M3 ៖ការកំណត់កាន់តែមានលក្ខណៈទូទៅនៃការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានគេទទួលយកជាផ្លូវការដោយប្រព័ន្ធទុនបម្រុងសហព័ន្ធ (Federal Reserve System) របស់សហរដ្ឋអាមេរិកគឺត្រូវបានគេតាងដោយប៉ារ៉ាមែត្រ M3ដែលរួមមាន M2 និងទ្រព្យមួយចំនួន[5]។

**២.១.៤ សារៈសំខាន់នៃរូបិយវត្ថុ**

មនុស្សជាច្រើនបានស្គាល់ពាក្យថារូបិយវត្ថុ ឬភាសាសាមញ្ញមួយហៅថា "លុយ" ប៉ុន្តែមានពេលខ្លះគេពិបាករកពាក្យមកពន្យល់ថា អ្វីទៅជាលុយនោះ ?តាមធម្មតាយើងអាចឱ្យនិយមន័យច្រើនយ៉ាងទៅលើពាក្យនេះ តែសម្រាប់អ្នកសិក្សាសេដ្ឋកិច្ច ជាពិសេសការគ្រប់គ្រងហិរញ្ញវត្ថុ និងធនាគារវិញ គេត្រូវការនិយមន័យដ៏ជាក់លាក់មួយសម្រាប់ការងារ និងសម្របសម្រួលដល់ការកំណត់ប្រើប្រាស់។

រូបិយវត្ថុ គឺជាអ្វីៗដែលត្រូវបានគេទទួលស្គាល់ជាទូទៅ និងត្រូវបានគេប្រើប្រាសដោយផ្ទាល់នៅក្នុងការទិញទំនិញ ឬសេវានានា។ ឬអាចហៅម្យ៉ាងទៀតថារូបិយវត្ថុ គឺជាមធ្យោបាយនៃការចាយវាយទូទាត់បំណុលដែលត្រូវបានគេ ទទួលស្គាល់ជាសកលនិងមាននៅក្នុងដៃអ្នកសេដ្ឋកិច្ចទៀត។ ជាការពិតណាស់និយមន័យនេះត្រូវបានគេប្រើប្រាស់ជាទូទៅប៉ុន្តែយើងក៏ត្រូវធ្វើការកត់សម្គាល់ថារូបិយប័ណ្ណដូចជាមូលប្បទានបត្រនិងប័ណ្ណឥណទានក៏ជារូបិយវត្ថុដែរព្រោះវាអាចបង្វិលជាប្រាក់កាកពីធនាគារបានហើយគេក៏អាចយកវាមកផ្ទេរដូចជាបរិមាណរូបិយវត្ថុ ដល់ជនណាម្នាកឬទិញទំនិញសេវាកម្ម បានដូចគ្នា។ ទន្ទឹមនឹងនេះផងដែរ បរិមាណរូបិយវត្ថុ គឺឆ្លុះបញ្ចាំងពីទ្រព្យសម្បត្តិ និងទ្រព្យទុនដទៃទៀត។ ឧទាហរណ៍៖ លោកគង់មានលុយច្រើនណាស់ មានន័យថាគាត់មានទ្រព្យសម្បត្តិច្រើន ដូចជាឡាន ផ្ទះ ក្រុមហ៊ុន និងអចលនទ្រព្យជាច្រើនទៀត។

១.រូបិយវត្ថុមានតួនាទីសំខាន់ពីរក្នុងសេដ្ឋកិច្ច៖

តួនាទីទីមួយ គឺសម្រាប់បែងចែកពលកម្ម និងជំនាញផលិតកម្មនៅក្នុងសង្គមអរិយធម៌ (The role of Money in economy is that the use of money allowed division of labor and specialization in the civilization world)។

តួនាទីទីពីរ គឺសម្រាប់ចូលរួមបង្កើតទ្រព្យនៅក្នុងសង្គម តាមរយៈការធ្វើជំនួញ និងពាណិជ្ជកម្ម ឬ តាមរយៈអត្រាការប្រាក់។

២.មុខងាររូបិយវត្ថុ (The Functions of Money)៖

រូបិយវត្ថុបានចូលរួមចំណែកក្នុងសេដ្ឋកិច្ច តាមរយៈការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនការធ្វើជំនួញនិងប្រើប្រាស់សេវាកម្មធនាគារជាដើម។ ដូចនេះរូបិយវត្ថុបានបំពេញមុខងារសំខាន់បីយ៉ាងទៀត គឺ៖

២.១ មធ្យោបាយដោះដូរ ឬគ្រឿងជំណូរ (Medium of Exchange)

គឺជាការធ្វើពាណិជ្ជកម្មរវាងទំនិញនិងទំនិញ ឬសេវានិងសេវាដោយគ្មានការប្រើប្រាស់ក្រដាសប្រាក់សម្រាប់ធ្វើការដោះដូរ ឬទូទាត់បំណុលជំនួសឡើង។

២.២ ឯកតាគណនី (Unit of Account)

---

[5] វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០២៤). *"រូបិយវត្ថុ និងធនាគារ(ភាគទី១)"* បោះពុម្ពលើកទី៦. ទំព័រទី១១-១២ ភ្នំពេញ

ឯកតាគណនី គឺជាខ្នាតសម្រាប់ធ្វើការវាស់វែងពី ស្ថានភាពថ្លៃណាមួយដែលអ្នកប្រើប្រាស់ ឬអតិថិជនបានគិតគូរអំពីតម្លៃសមស្របនៃទំនិញ និងសេវាកម្មដែលគេចង់បាន។

២.៣ ការរក្សា ឬបន្ទុកតម្លៃ ( Stores of Value )

សំដៅទៅលើផលិតផលទាំងឡាយ ឬវត្ថុតាងនានាដែលអាចយកទៅប្រើប្រាស់ជាថ្នូរក្នុងការដោះដូរផលិតផល ក្រោយពីការកាន់កាប់មួយរយៈ ។

៣.ទម្រង់រូបិយវត្ថុ ( Forms of Money )

ទម្រង់រូបិយវត្ថុ អាចប្រែប្រួលតាមប្រព័ន្ធរូបិយវត្ថុដែលទាក់ទងនឹងសម័យកាល និងតាមតំបន់នានា។ ដូចនេះទម្រង់រូបិយវត្ថុមានដូចខាងក្រោមនេះ៖

៣.១ ផលិតផលរូបិយវត្ថុ ( Commodity Money )

គឺជាលក្ខណៈរបស់ផលិតផលមួយដែលមានតម្លៃពិតប្រាកដហើយគេក៏អាចប្រើប្រាស់វាជាមធ្យោបាយសម្រាប់ការដោះដូរ។

៣.២ រូបិយវត្ថុក្រដាស ( Paper Money )

គឺជាក្រដាសទាំងឡាយណាដែលអាចបញ្ជាក់ពីលទ្ធភាពនៃការដោះដូរ ឬទិញលក់បានតាមរយៈការចេញឱ្យចរាចរនៅលើទីផ្សារដោយធនាគារជាតិ ឬធនាគារកណ្តាល។

៣.៣ ក្រឹត្យរូបិយវត្ថុ ( Fiat Money )

គឺជាក្រដាសប្រាក់ និងកាក់ ដែលត្រូវបានគេស្គាល់នាពេលបច្ចុប្បន្ន ដោយមានភាពជឿជាក់។

៣.៤ បញ្ញើរូបិយវត្ថុ ( Deposit Money )

គឺជាលុយដែលបានដាក់ចូលក្នុងគណនីអេឡិចត្រូនិកនៅក្នុងធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ដូចជាមូលប្បទានបត្រ ប័ណ្ណឥណទាន ឬឥណពន្ធ[6]។

## ២.២ នីតិវិធីក្នុងការប្រើប្រាស់ប្រាក់រៀលឱ្យមានប្រសិទ្ធភាព

### ២.២.១ និយមន័យនីតិ

នីតិ គឺជាវិធានការទាំងឡាយដែលគ្រប់គ្រងជីវភាពរស់នៅក្នុងសង្គមដោយមានការដាក់ទណ្ឌកម្មពីអំណាចសាធារណៈ[7]។

នីតិ ជាបណ្តុំវិធានគតិយុត្តទាំងឡាយដែលមានគោលដៅធ្វើអោយសង្គមមនុស្សមានសណ្តាប់ធ្នាប់ និងអមមកជាមួយដោយទណ្ឌកម្ម[8]។

### ២.២.២ ប្រភពនីតិ

[6] វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០២៤). *រូបិយវត្ថុ និងធនាគារ(ភាគទី១).* បោះពុម្ពលើកទី៦ ទំព័រទី៦-១០ ភ្នំពេញ

[7] វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០១៩). *សេចក្តីផ្តើមនៃនីតិ.* បោះពុម្ពលើកទី៨. ទំព័រទី២. ១១០ទំព័រ ភ្នំពេញ

[8] KHINFO. (2021, December 16). *ចូរឱ្យនិយមន័យនីតិ.* Retrieved from https://www.facebook.com

នៅសម័យសង្គមបុព្វកាលមនុស្សរស់នៅដោយគ្មានច្បាប់អ្វីទេ ប៉ុន្តែមនុស្សអាចរស់នៅជាមួយគ្នាបានហើយថែមទាំងមានការគោរពគ្នាទៅវិញទៅមកទៀតផង។ ការរស់នៅរបៀបនេះគឺជាការរស់នៅតាមការគោរពនូវទំនៀមទម្លាប់ប្រពៃណី និងសាសនាជាដើម។ ប៉ុន្តែក្នុងពេលខ្លះក៏មានការរំលោភ ការធ្វើបាប ការជិះជាន់ ការកេងប្រវ័ញ្ច នឹងការជំទាស់ប្រឆាំងគ្នាជានិរន្តរ៍ផងដែរ ។ ទង្វើបែបនេះធ្វើឱ្យមនុស្សយល់ ថាគួរតែរៀបចំឱ្យមាននូវឆន្ទៈរួមមួយ។ ឆន្ទៈរួមនេះធ្វើឱ្យការរស់នៅរបស់មនុស្សតាមទម្លាប់ខាងលើមានការវិវត្តន៍ទៅជាការរៀបចំនូវក្បួនខ្នាតមួយចំនួន ដើម្បីជាការរក្សាទុកក៏ដូចជាការបន្តការគោរពនូវទំនៀមទម្លាប់ប្រពៃណីខាងលើនាពេលក្រោយៗទៀត។

ភស្តុតាងជាក់ស្តែងជាច្រើនបានបង្ហាញឱ្យឃើញថា ច្បាប់បានចាប់កកើតឡើងតាំងពីយូរយារណាស់មកហើយ ពោលគឺតាំងពីសម័យដើមមកម្ល៉េះ គឺតាំងពីសម័យកាលដែលមនុស្សចេះរួបរួមគ្នារស់នៅជាក្រុម ជាពួកជាកុលសម្ព័ន្ធដោយត្រូវមានក្រុមមេពួក ឬមេកន្ទ្រាញ (ស្តេចត្រាញ់)។ មេក្រុម មេពួក មេកន្ទ្រាញ តែងតែរិះរកគំនិត និងវិធានផ្សេងៗ ដើម្បីធ្វើការគ្រប់គ្រងកូនចៅរបស់ខ្លួន។ ការគ្រប់គ្រងនេះហើយដែលជាការចាប់ផ្តើមកកើតនូវច្បាប់មួយដែលមេក្រុម មេពួក ឬមេកន្ទ្រាញខ្លះគ្រប់គ្រងតាមបែបផ្តាច់ការ និង ខ្លះមិនផ្តាច់ការ។ រហូតដល់មានជាការគ្រប់គ្រងដោយព្រះរាជា ដែលព្រះរាជាធ្វើការគ្រប់គ្រងនគរ ការពារអំណាច ការពារតំណែង និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជារាស្ត្របាន។

យ៉ាងណាមិញនៅប្រទេសកម្ពុជា យើងអាចប្រមើលឃើញថា តើមានការលំបាកយ៉ាងណាខ្លះក្នុងបេសកកម្មកសាងប្រាសាទអង្គរវត្ត។ ជាការពិតណាស់ក្នុងដំណើរការនៃការកសាងនេះ គឺពិតជាមានការលំបាក យ៉ាងខ្លាំងទាំងបច្ចេកទេស ធនធាន និងការគ្រប់គ្រងពិសេសគឺការសាងសង់។ ដើម្បីដោះស្រាយបញ្ហាទាំង នេះគឺត្រូវទាមទារឱ្យមាននូវច្បាប់នៃការគ្រប់គ្រងសង្គមមួយដ៏មានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ដូចនេះ យើងអាចនិយាយជារួមបានថាច្បាប់គឺពិតជាមានតាំងពីយូរយារណាស់មកហើយ គ្រាន់តែយើងមិនមានឯកសារបញ្ជាក់ច្បាស់លាស់តែប៉ុណ្ណោះ ប៉ុន្តែយើងអាចមើលទៅលើភស្តុតាងមួយចំនួនដែល បន្សល់ទុកដូចជាប្រាសាទអង្គរវត្ត មហាកំពែងចិន។ល។ ដែលសុទ្ធតែជាភស្តុតាងបញ្ជាក់អំពីការកកើតច្បាប់។ ដូចនេះ តើច្បាប់ជាអ្វី? ហើយនីតិជាអ្វី?

នីតិ (Law/droit) គឺជាវិទ្យាសាស្ត្រច្បាប់ សិក្សាលើសំណុំវិធានទាំងឡាយណា ដែលមនុស្សជាអ្នកបង្កើតឡើងដើម្បីគ្រប់គ្រងការរស់នៅ និង គ្រប់គ្រងការទំនាក់ទំនងរបស់មនុស្សក្នុងសង្គមតាមរយៈការអនុវត្តន៍ និងផ្តន្ទាទោស(ដាក់ទណ្ឌកម្ម) ដោយអំណាចសាធារណៈ ។ លើសពីនេះទៅទៀតនីតិជាមធ្យោបាយដោះស្រាយទំនាស់ក្នុងសង្គម។

ច្បាប់ (Law) មានអត្ថន័យពីរគឺច្បាប់ក្នុងន័យចង្អៀត និងច្បាប់ក្នុងន័យទូលាយ។

- ក្នុងន័យទូលាយ ច្បាប់ជាវិធាននៃឥរិយាបថជាផ្លូវការ ឬជាឧបករណ៍ដើម្បីការពារ និងអភិវឌ្ឍតម្លៃនៃសង្គម។

- ក្នុងន័យចង្អៀត ច្បាប់ខុសពីនីតិត្រង់ថាច្បាប់គឺជាវិធានគតិយុត្តិដែលរៀបចំ និងតាក់តែងឡើងដោយអង្គការនីតិបញ្ញត្តិ (រដ្ឋសភា និងព្រឹទ្ធសភា) និងត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ[9]។

**២.២.៣ ទ្រឹស្តីនីតិ**

**១.ច្បាប់នៅក្នុងនីតិសាស្ត្រពិភពលោក**

ច្បាប់ជាបាតុភូតប្លែកពីធម្មតា ស្មុគស្មាញនិងជាបាតុភូតចាំបាច់ទូទៅ អញ្ចឹងហើយនៅក្នុងរយៈពេលទាំងអស់ នៃការកកើតមានឡើង វត្តមានរបស់វា ផលប្រយោជន៍វិទ្យាសាស្ត្រ មិនត្រឹមតែមិនរលាយសាបសូន្យនោះទេតែថែមទាំងរីកដុះដាលថែមទៀតចំពោះច្បាប់។

ការយល់ដឹងច្បាប់ (Legal Understanding) គឺជាប្រភេទវិទ្យាសាស្ត្រដែលឆ្លុះបញ្ចាំងអំពីដំណើរការនិងលទ្ធផលនៃសកម្មភាពប្រកបដោយចេតនារបស់មនុស្ស ដែលនាំមកជាមួយនូវការយល់ដឹងអំពីច្បាប់សតិសាម្បជ្ជៈរបស់ខ្លួន និង ទំនាក់ទំនងទៅនិងមនុស្សក៏ដូចជា ទំនាក់ទំនងទៅនឹងបាតុភូតសង្គមរួមគ្នាទាំងមូលដែរ ។

**ទ្រឹស្តីទស្សនវិជ្ជមានរបស់ច្បាប់៖** បានកើតឡើងនៅក្នុងកំរិតមួយយ៉ាងសំខាន់ដូចជាទ្រឹស្តីប្រឆាំងនឹងច្បាប់ ធម្មជាតិ។

**ទ្រឹស្តីបទដ្ឋាន** (Normative Theory)**៖** ដែលកើតឡើងទៅលើមូលដ្ឋាននៃការបង្ហាញឱ្យឃើញ គឺជាបណ្តុំ ឬ ពហុភាពនៃបទដ្ឋានដែលស្តែងចេញមកខាងក្រៅ នៅក្នុងច្បាប់ និង នៅក្នុងលិខិតបទដ្ឋានផ្សេងទៀត ។

**ទ្រឹស្តីចិត្តវិជ្ជា** (Psychological Theory) លោក Petrazitski ជាស្ថាបនិកនៃទ្រឹស្តីនេះ៖ គាត់ទទួលស្គាល់ថាច្បាប់ គឺជាតថភាពនៃចិត្តសាស្ត្រ (Psychological) ហេតុការណ៍ដែលកើតឡើងពិតផ្នែកចិត្តសាស្ត្រគឺជា ការរំជួលចិត្តផ្នែកច្បាប់ (Legal Emotion) របស់មនុស្ស។

**ទ្រឹស្តីសង្គមសាស្ត្ររបស់ច្បាប់** (Sociological Theory of law) បានកើតឡើងនៅពេលពាក់កណ្តាលសតវត្សទី ១៦ ទ្រឹស្តីនេះបានកត់សំគាល់ច្បាប់ទុកដូចជាបាតុភូតដែលសំអាងលើបទពិសោធន៍។ភស្តុតាងដ៏សំខាន់របស់ទ្រឹស្តីនេះកើតឡើងត្រង់ថាច្បាប់ និងស្វែងរកការពិតមិនមែន នៅក្នុងបទដ្ឋានតែនៅក្នុងជីវភាព ឬ ជីវិតពិត ។

**២.ទស្សនទានច្បាប់** (Conception of law)

នៅក្នុងវិទ្យាសាស្ត្រនីតិសាស្ត្រជឿនលឿនពាក្យ នីតិឬច្បាប់ត្រូវបានប្រើប្រាស់នៅក្នុងន័យ ឬ អត្ថន័យមួយចំនួន ។

**ទីមួយ៖** សេចក្តីត្រូវការផ្នែកច្បាប់ទូទៅការទាមទារផ្នែកសង្គមទាំងអស់នេះហៅថាច្បាប់ចុះ សិទ្ធិរបស់មនុស្សក្នុងការរស់នៅសិទ្ធិរបស់ពលរដ្ឋដោយខ្លួនឯង ការសំរេចចិត្តដោយខ្លួនឯង និង សិទ្ធិផ្សេងៗទៀត។

**ទីពីរ៖** ច្បាប់យល់ថាជាប្រព័ន្ធបទដ្ឋាននីតិ ប្រព័ន្ធបទដ្ឋាននីតិនេះគឺជាច្បាប់នៅក្នុងន័យវត្ថុវិស័យសម្រាប់បទដ្ឋាន នៃច្បាប់ត្រូវបានបង្កើតឡើង និងធ្វើសកម្មភាពមិនអាស្រ័យនឹងឆន្ទៈបុគ្គលឡើយ។

---

[9] វិទ្យាស្ថាន វ៉ាន់ដា. (ឆ្នាំ២០១៩). *សេចក្តីផ្តើមនៃនីតិ*. បោះពុម្ពលើកទី៨. ទំព័រទី៣. ១១០ទំព័រ. ភ្នំពេញ

**ទីបី៖** ពាក្យដែលបានហៅមកនេះមានន័យថាជាលទ្ធភាពដែលទទួលស្គាល់ជាផ្លូវការដែលរូបវន្តបុគ្គល ឬ នីតិបុគ្គល អង្គការទាំងឡាយមាន។

**ទីបួន៖** ពាក្យ «នីតិឬច្បាប់ឬសិទ្ធិ» ត្រូវបានប្រើប្រាស់សំរាប់ការបញ្ជាក់ន័យរបស់ប្រពន្ធ័នៃបាតុភូតច្បាប់ទាំងអស់។

**ច្បាប់** គឺជាធម្មជាតិកំណត់របស់មនុស្ស និងសង្គមដែលជាប្រពន្ធ័ឆ្លុះបញ្ចាំងនៃនិយ័តកម្មទំនាក់ទំនងសង្គម ទៅលើសេរីភាពរបស់បុគ្គលដែលមានភាពត្រឹមត្រូវផ្ទាល់របស់ខ្លួន ។

**៣. នីតិ និងច្បាប់** (Law and Statute)

បញ្ហាស្តីអំពីការទាក់ទងគ្នាទៅវិញទៅមករបស់នីតិ និង ច្បាប់ធ្វើឱ្យមានការខ្វែងគំនិតគ្នាជាច្រើននៅក្នុងស្នាដៃនិពន្ធនីតិសាស្ត្រ។

ច្បាប់ដូចនេះអាចកំណត់ទុកដូចជានីតិទម្រង់(Formal law) បានសេចក្តីថា នីតិយល់ឃើញជាទម្រង់ប៉ុន្តែមិនមែនជាខ្លឹមសារឬសារជាតិទេ។

## ២.៣ ការប្រើប្រាស់ប្រាក់រៀលជួយលើកស្ទួយដល់សេដ្ឋកិច្ចជាតិ

### ២.៣.១ និយមន័យសេដ្ឋកិច្ច

**សេដ្ឋកិច្ច** គឺជាយន្តការមួយដែលទាក់ទងនឹងការចាត់ចែងប្រើប្រាស់ធនធានដើម្បីបំពេញចង់បានរបស់សង្គម[10]។

**សេដ្ឋកិច្ច** គឺជាសំណុំនៃទំនាក់ទំនង ផលិតកម្ម ការប្រើប្រាស់ ការដោះដូរ និងការបែងចែងធនធានកម្រទាំងឡាយនៅក្នុងសង្គម[11]។

**សេដ្ឋកិច្ច** ជាការសិក្សាពីរបៀបដែលបុគ្គលគ្រួសារសង្គមចេះលៃលកប្រើប្រាស់នូវធនធានដែលមានក្នុងការផលិត ( ទំនិញនិងសេវាកម្ម) ដើម្បីបម្រើសេចក្តីត្រូវការឥតព្រំដែនរបស់មនុស្ស[12]។

### ២.៣.២ ប្រវត្តិនៃសេដ្ឋកិច្ច

ការលើកយកប្រវត្តិសេដ្ឋកិច្ចមកសិក្សា គឺមានគោលដៅធំបំផុតមួយ ពោលគឺយើង ចង់សិក្សាស្វែងយល់អំពីបាតុភូតសេដ្ឋកិច្ច (Economic phenomena) ។ ជាការពិត ប្រសិនជា យើងមានបំណងធ្វើការវិភាគលើបាតុភូតសេដ្ឋកិច្ចឱ្យមានលក្ខណៈសុក្រឹត ជាដំបូង យើងត្រូវ តែស្គាល់ឱ្យបានច្បាស់អំពីប្រវត្តិគំនិតសេដ្ឋកិច្ច (History of economics thought), ប្រវត្តិវិភាគសេដ្ឋកិច្ច (History of economic analysis) និងប្រវត្តិលទ្ធិសេដ្ឋកិច្ច (History of economics doctrines)។ តែនៅក្នុងចំណុចនេះ យើងមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីធ្វើការបង្ហាញអំពីពួកវាឱ្យ បានពិស្តារនោះឡើយ ដោយគ្រាន់តែមានការបង្ហាញពីដំណើរដើមទងតែបន្តិចបន្តួចប៉ុណ្ណោះ។

ការសរសេរប្រវត្តិសេដ្ឋកិច្ចតម្រូវឱ្យមានការចងក្រងនូវប្រវត្តិជាច្រើនរួមគ្នា។ តែវាជាការចាំបាច់បំផុតដែលយើងទាំងអស់ត្រូវតែស្គាល់ឱ្យបានច្បាស់អំពីប្រវត្តិរបស់មនុស្ស ដែលបានបង្កើតឱ្យមានការយកចិត្ត

---

[10] វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០១២). *មីក្រូសេដ្ឋកិច្ចវិទ្យា*. បោះពុម្ពលើកទី៣. ទំព័រទី៤. ភ្នំពេញ។

[11] KHsearch. Changheng Menh. (2021, May 04). *តើសេដ្ឋកិច្ចជាអ្វី?* Retrieved from https://www.khsearch.com/qna/13654

[12] KHsearch. ទីផ្សារ. (Jul 9, 2019). *អ្វីទៅជានិយមន័យសេដ្ឋកិច្ច?* Retrieved from https://www.khsearch.com/qna/22672

ទុកដាក់ទៅលើសេដ្ឋកិច្ចពោលគឺប្រវត្តិសេដ្ឋវិទូដែលបានចូលរួមចំណែកនៅក្នុងការកសាងទ្រឹស្តីសេដ្ឋកិច្ច ដើម្បីសុភមង្គលរបស់មនុស្សទូទៅ។

ដូច្នេះការចងក្រងប្រវត្តិគំនិតសេដ្ឋកិច្ចអាចកើតមានឡើងបាន ដោយអាស្រ័យទៅលើការប្រមូលនូវគំនិត និងព័ត៌មានផ្សេងៗ ដែលមានការជាប់ទាក់ទងទៅនឹងមុខវិជ្ជា និង ផ្នែកផ្សេងៗទៀតជាច្រើន។ ជាទូទៅ ប្រវត្តិសេដ្ឋកិច្ចត្រូវបានគេរៀបចំនៅក្នុងទម្រង់ និង មានការពន្យល់ខុសគ្នាដោយអន្លើដោយយោងទៅលើគំនិត និងការចង់បានរបស់អ្នកចងក្រង និងស្ថិតនៅក្នុងគោលដៅដោយឡែកពីគ្នា។ ប្រវត្តិគំនិតសេដ្ឋកិច្ចមិនវិនិច្ឆ័យថាតើគំនិតសេដ្ឋកិច្ចរបស់ សេដ្ឋវិទូ ឬបញ្ញវន្ត ណាមួយត្រូវ ឬណាមួយខុសនោះឡើយ តែផ្ទុយទៅវិញ វាមានតួនាទី ត្រឹមតែបង្ហាញអំពី ដំណើរវិវត្តន៍ និងការប្រែប្រួលនូវគំនិតសេដ្ឋកិច្ច ដែលមានជាយូរលង់ណាស់មកហើយ[13]។

**២.៣.៣ ទ្រឹស្តីនៃសេដ្ឋកិច្ច**

រហូតមកដល់ពេលនេះ ការពិភាក្សាទៅលើថាតើសេដ្ឋកិច្ច និងបាតុភូតសេដ្ឋកិច្ច ជាអ្វីនោះនៅតែបន្តមាន។ ប៉ុន្តែការណ៍នេះមិនមែនមានន័យថា សេដ្ឋកិច្ចមានលក្ខណៈស្មុគស្មាញរហូតទាល់តែមិនអាចធ្វើការកំណត់និយមន័យបាននោះឡើយ។ និយមន័យសេដ្ឋកិច្ច ដែលត្រូវបានប្រើយ៉ាងទូលំទូលាយមួយដែលផ្តល់ដោយលីអូណែលរូប៊ីន (Lionel Robbins) "សេដ្ឋកិច្ចគឺជាវិទ្យាសាស្ត្រដែលសិក្សាអំពីឥរិយាបថរបស់មនុស្ស ដែលជាប់ទាក់ទងទៅនឹង ធនធានដែលមនុស្សបានប្រើក្នុងវិធីផ្សេងៗគ្នា"។ បាតុភូតសេដ្ឋកិច្ច ដែលក្នុងនោះរួមមាន ដូចជាថ្លៃ, លុយ, ផលិតកម្ម, និងទីផ្សារជាដើម អាចត្រូវបានចាត់ទុកថា បណ្តាលមកពី លទ្ធផលនៃភាពកម្រ ឬជាវិធីដែលមនុស្សព្យាយាមពុះពារអំពីបញ្ហានៃភាពកម្រ។ ការកំណត់ និយមន័យនៃពាក្យសេដ្ឋកិច្ចរបស់រូប៊ីន គឺមានគោលបំណងចាប់យកលក្ខណៈពិសេស ដែល កើតមានជាធម្មតាចំពោះសេដ្ឋកិច្ច ដែលត្រូវបានស្គាល់ថាជា "បញ្ហាសេដ្ឋកិច្ច" ហើយនិយមន័យនេះ បានបង្ហាញអំពីទស្សនៈដ៏ច្បាស់លាស់មួយតែទោះបីជាយ៉ាងណា ទស្សនៈនេះ នៅ មានភាពចង្អៀតចង្អល់នៅឡើយ ទាក់ទងនឹងលក្ខណៈជាក់ស្តែងនៃបញ្ហាសេដ្ឋកិច្ច។

ការកំណត់និយមន័យដែលមានលក្ខណៈប្រសើរជាងនេះ គឺស្ថិតក្នុងសម័យរបស់ មហាក្សត្រីយានីវិចតូរីយ៉ាដែលសេដ្ឋវិទូ អាល់ហ្វ្រេដ ម៉ាហ្សាល (Alfred Malshall) ធ្វើការកំណត់និយមន័យសេដ្ឋកិច្ចថា "ជាការសិក្សារបស់មនុស្សនៅក្នុងអាជីវកម្មធម្មតានៃជីវិតរស់នៅ"។ តាមរយៈការកំណត់និយមន័យនេះ យើងបានយល់ពីអ្វីដែលគាត់មានបំណងឆ្ពោះទៅរកហើយវាក៏ជាការពិបាកដែរនៅក្នុងការមិនយល់ស្របតាម។ ទោះបីជាយ៉ាងនេះក្តី និយមន័យរបស់លោកមានលក្ខណៈមិនច្បាស់លាស់ទាល់តែសោះ ប៉ុន្តែគេអាចបញ្ជាក់និយមន័យសេដ្ឋកិច្ចដែលមានលក្ខណៈច្បាស់ជាងនេះ ដោយកំណត់ថា "សេដ្ឋកិច្ចទាក់ទងនឹង ផលិតកម្ម (Production).ការបែងចែក (Distribution) និងការប្រើប្រាស់ទ្រព្យសម្បត្តិ (Consumption of wealth) ឬកាន់តែច្បាស់ជាងនេះទៅទៀតនោះ "សេដ្ឋកិច្ចគឺសិក្សាអំពីរបៀបដែលផលិតកម្មត្រូវបានរៀបចំ ដើម្បីបំពេញ

---

[13] សាកលវិទ្យាល័យជាតិគ្រប់គ្រង. អ្នករៀបរៀង: ស៊ុំ សុចិន្តា. *"ប្រវត្តិគំនិតសេដ្ឋកិច្ច (សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន)"*

តម្រូវការ និងការចង់បានរបស់មនុស្ស"។ និយមន័យផ្សេងទៀតបានកំណត់ថា "សេដ្ឋកិច្ចគឺជាតក្កភាពនៃការជ្រើសរើស ឬជាការសិក្សាអំពីទីផ្សារ។

ប្រហែលជាសំខាន់ដូចអ្វីដែលនិយមន័យទាំងនេះបាននិយាយ គឺជាអ្វីដែលពួកគេ មិនបាននិយាយ។ បញ្ហាដែលជាប្រធានបទរបស់សេដ្ឋកិច្ចមិនត្រូវបានកំណត់ថាជា "ការទិញ និងលក់ទំនិញ, ទីផ្សារ, អង្គភាពអាជីវកម្ម, ទីផ្សារហ៊ុន ឬសូម្បីតែលុយ" ឡើយ។ ទាំងអស់នេះសុទ្ធសឹងជាបាតុភូតសេដ្ឋកិច្ច ប៉ុន្តែមានសង្គមខ្លះដែលគេសង្កេតឃើញថា មិនមានពួកវា កើតឡើងឡើយ។ សង្គមបែបនេះនឹងជួបប្រទះបញ្ហាសេដ្ឋកិច្ចពោលគឺត្រូវផលិតទំនិញដោយរបៀបណា, បែងចែកទំនិញនោះយ៉ាងដូចម្តេច, បែងចែកនៅពេលណា ហើយនរណានឹងទទួលបានទំនិញទាំងនេះជា ដើម។ បាតុភូតសេដ្ឋកិច្ចដូចជាសហគ្រាស (Firms), ទីផ្សារហ៊ុន (Stock exchange), និង លុយ (Money)ជាដើម ត្រូវបានចាត់ទុកថាជាឧបករណ៍មួយដ៏ប្រសើរនៅក្នុងការដោះស្រាយបញ្ហាជាមូលដ្ឋានរបស់សេដ្ឋកិច្ច និងមានលក្ខណៈដ៏សាមញ្ញសម្រាប់សង្គមទាំងឡាយ។ ដូច្នេះវាជាការប្រសើរនៅក្នុងការកំណត់និយមន័យ សេដ្ឋកិច្ចឱ្យមានការជាប់ទាក់ទងទៅនឹងបញ្ហាជាមូលដ្ឋានទាំងអស់នេះជាជាងទាក់ទងទៅនឹងឧបករណ៍ដែលកើតមានក្នុងសង្គមមួយចំនួនតែផ្ទុយទៅវិញពួកវាមិនមាននៅក្នុងបណ្តាសង្គមផ្សេងទៀតនោះ។

អ្នកចងក្រង "គោលការណ៍សេដ្ឋកិច្ច" (Principles of economics) បានសម្រេចអំពីការដាក់និយមន័យដ៏ច្បាស់លាស់មួយទាក់ទងនឹងប្រធានបទ និងកិច្ចការដែលមាននៅ ក្នុងសេដ្ឋកិច្ច។ ប្រាសទៅវិញ វាអាចទៅរួចក្នុងការចាប់ផ្តើមជាមួយនឹងគំនិតទាំងនោះដែលនាំឱ្យមានសេដ្ឋកិច្ចសហសម័យ ឬ ទំនើប (Contemporary economics) ពោលគឺជាគំនិតដែលត្រូវបានរកឃើញនៅក្នុងការបង្រៀនសេដ្ឋកិច្ច និងកំពុងត្រូវបានយកមកអភិវឌ្ឍដោយសេដ្ឋវិទូ។ ដូច្នេះវាមានន័យថាព្រំដែនរបស់សេដ្ឋកិច្ចមិនមានភាពច្បាស់លាស់នោះឡើយ ដោយសារតែថាបញ្ហាសេដ្ឋកិច្ចត្រូវបានវិភាគមិនមែនត្រឹមតែ "សេដ្ឋវិទូ"ប៉ុណ្ណោះទេថែមទាំងប្រវត្តិវិទូ (Historians), ភូមិសាស្ត្រវិទូ (Geographers), បរិស្ថានវិទូ (Ecologists), អ្នកវិទ្យាសាស្ត្រខាងផ្នែកគ្រប់គ្រង (Management scientists) និងវិស្វករ (Enginers)ទៀតផង។ ប៉ុន្តែការសរសេរចងក្រង និងលើកឡើងរបស់ពួកគេមិនមែនជាអ្វី ដែលសេដ្ឋវិទូវិជ្ជាជីវៈត្រូវយកមកពិចារណា ដើម្បីធ្វើការត្រួតពិនិត្យទៅលើសេដ្ឋកិច្ច ប្រកបដោយសុក្រិនិច្ឆ័យឡើយ ដែលការណ៍នេះឆ្លុះបញ្ចាំងឱ្យឃើញថា ការជជែកវែកញែករបស់ពួកគេទាំងនោះ គ្រាន់តែជាការបំភាន់តែប៉ុណ្ណោះ។ ប៉ុន្តែវានៅតែជាសេដ្ឋកិច្ច។ ដូច្នេះយើងអាចនិយាយបានថាការត្រិះរិះពិចារណា និងការវិភាគក្នុងមធ្យោបាយដ៏តឹងតែងរបស់សេដ្ឋវិទូ គឺជាមធ្យោបាយមួយដើម្បីឆ្លើយតបទៅនឹងអ្វីដែលបណ្តាប្រវត្តិវិទូ ឬអ្នកផ្សេងទៀតបានគិតអំពីបញ្ហាសេដ្ឋកិច្ច។

ចំពោះឫសគល់នៃគំនិតសេដ្ឋកិច្ច ដែលត្រូវបានប្រវត្តិវិទូនៅតែចាត់ទុកថាជា សេដ្ឋកិច្ចសូម្បីតែការបកស្រាយ និងការអធិប្បាយរបស់ពួកគេមានលក្ខណៈខុសគ្នាយ៉ាង ខ្លាំងពីគំនិតសេដ្ឋកិច្ចសម័យទំនើបនឹងត្រូវបានរាប់បញ្ចូលទៅក្នុងប្រវត្តិសាស្ត្រ។ ជាលទ្ធផលនៃការជ្រើសរើសមួយបែបនេះ គឺស្ថិតក្នុងគោលបំណងមួយដើម្បីជៀសវាងនូវគំនិតសង្ស័យដែលចេះតែបន្តមាន ថាតើគំនិតសេដ្ឋកិច្ចដ៏ពិតប្រាកដមានដែរឬទេ? មានមនុស្សខ្លះអះអាងថាអ្នកចងក្រង ឬ អ្នកនិពន្ធមុនៗមិនគួរត្រូវបានចាត់ទុកថាជាសេដ្ឋវិទូនោះឡើយ ដោយពួកគេសំអាងថាមានតែបុគ្គល ឬក្រុមពិសេសណាមួយនោះទេ ដែលជាស្ថាបនិកសេដ្ឋកិច្ចដ៏ពិតប្រាកដ។

ក្នុងន័យនេះ យើងអាចធ្វើការសង្ខេបឡើងវិញបានថា សេដ្ឋកិច្ចមិនមានអ្នកណាម្នាក់បង្កើតនោះឡើយ ពោលគឺថា មនុស្សតែងតែបានគិតអំពីសំនួរដែលយើងឥឡូវនេះបានគិតនិងត្រិះរិះពិចារណាទៅលើផ្នែកនៃសេដ្ឋកិច្ច។នៅក្នុងសៀវភៅនេះយើងនឹងត្រួតពិនិត្យ ជាដំបូងទៅលើគំនិតសេដ្ឋកិច្ចដោយ ផ្ដើមចេញពីក្រិចបុរាណ (Ancient Greece) និងពិភព នៃគម្ពីរចាស់ (World of Old Testament) រហូតមកដល់សម័យទំនើប។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី អ្វីដែលចាប់ផ្ដើមពីដំបូងនេះមិនមែនតំណាងឱ្យបដិសន្ធិ ឬការចាប់ផ្ដើមនៃគំនិតសេដ្ឋកិច្ចនោះឡើយ[14]។

[14] សាកលវិទ្យាល័យជាតិគ្រប់គ្រង, អ្នករៀបរៀង: ស៊ុំ សុចិន្តា. "ប្រវត្តិគំនិតសេដ្ឋកិច្ច (សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន)"

# ជំពូកទី៣

# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣

# អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល

## ៣.១ ស្ថានភាពទូទៅរបស់ធនាគារជាតិនៃកម្ពុជា

### ៣.១.១ ប្រវត្តិនៃការកកើត និងការអភិវឌ្ឍន៍របស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាមានប្រវត្តិយូរអង្វែង ដែលអាចបែងចែកជាបួនដំណាក់កាលដូចខាងក្រោម៖

១) ដំណាក់កាលពីឆ្នាំ ១៩៥៤ ដល់ឆ្នាំ ១៩៦៤៖ ប្រទេសកម្ពុជាបានទទួលបានឯករាជ្យពីអាណានិគមនិយមបារាំងក្នុងឆ្នាំ១៩៥៣ ហើយធនាគារជាតិនៃកម្ពុជាក៏ត្រូវបានបង្កើតឡើង ។ ធនាគារជាតិនៃកម្ពុជាទទួលភារៈផ្តាច់មុខជាអ្នកបោះពុម្ពប្រាក់រៀល ដែលជារូបិយវត្ថុជាតិ និងគ្រប់គ្រងប្រព័ន្ធធនាគារនៅកម្ពុជា។

២) ដំណាក់កាលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩៖ ធនាគារជាតិនៃកម្ពុជាត្រូវបានបិទដោយសាររបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ។ អគារស្នាក់ការត្រូវបានកម្ទេចរូបិយវត្ថុជាតិត្រូវបានឈប់ប្រើប្រាស់ ហើយប្រព័ន្ធធនាគារត្រូវបានលុបបំបាត់ចោលទាំងស្រុង ។

៣) ដំណាក់កាលពីឆ្នាំ ១៩៧៩ ដល់ ១៩៩៣៖ ធនាគារជាតិនៃកម្ពុជាត្រូវបានកសាងឡើងវិញពីចំណុចសូន្យ ។ ទន្ទឹមនេះ រូបិយវត្ថុជាតិក៏ត្រូវបានបោះផ្សាយឡើងវិញ។ កម្ពុជាបានប្តូរពីសេដ្ឋកិច្ចផែនការទៅជាសេដ្ឋកិច្ចទីផ្សារសេរី ។

៤) ដំណាក់កាលពីឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន៖ ប្រព័ន្ធធនាគារត្រូវបានពង្រឹង និងធ្វើទំនើបភាវូបនីយកម្មជាលំដាប់ហើយកម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្លាំងជាងគេនៅលើពិភពលោក ។

**ឯករាជ្យភាព និងការបង្កើតឡើងវិញ (១៩៥៤-១៩៦៤)**

ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងនៅខែធ្នូ ឆ្នាំ១៩៥៤ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យពីអានិគមនិយមបារាំង និងបន្ទាប់ពីវិទ្យាស្ថានបោះប្រាក់ឥណ្ឌូចិនត្រូវបានបិទទ្វារ។

មុនទទួលបានឯករាជ្យ វិទ្យាស្ថានបោះប្រាក់ដែលទីតាំងនៅប្រទេសកម្ពុជា បានបោះពុម្ពរូបិយវត្ថុរួមគ្នាសម្រាប់បីប្រទេសនៅឥណ្ឌូចិនគឺ ប្រទេសកម្ពុជា ប្រទេសឡាវ និងវៀតណាម។

បន្ទាប់ពីទទួលបានឯករាជ្យ ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយរូបិយវត្ថុជាតិ (ប្រាក់រៀល) ដើម្បីបំពេញអធិបតេយ្យភាពក្នុងការរក្សាស្ថិរភាពរូបិយវត្ថុ និងជួយកសាងអត្តសញ្ញាណជាតិ។ ក្នុងពេលនោះដែរប្រព័ន្ធធនាគារក្នុងស្រុកត្រូវបានកសាងឡើងវិញ ដែលមានទាំងធនាគាររដ្ឋ និងឯកជនធ្វើប្រតិបត្តិការរួមគ្នា។

ក្នុងសម័យសង្គមរាស្ត្រនិយមនាទសវត្សឆ្នាំ១៩៦០ ក្រោមការដឹកនាំរបស់ព្រះបាទនរោត្តមសីហនុព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍន៍រីកចម្រើនទូទាំងផ្ទៃប្រទេស។ នៅឆ្នាំ១៩៦៤ ប្រព័ន្ធធនាគារត្រូវបានធ្វើកំណែទម្រង់ដើម្បីឱ្យត្រូវតាមតម្រូវការសេដ្ឋកិច្ចនិងការអភិវឌ្ឍនាសម័យនោះ ដោយបានប្រែក្លាយធនាគារជាតិនៃកម្ពុជាពីទម្រង់ស្ថាប័នពាក់កណ្តាលស្វ័យត ទៅជាធនាគាររដ្ឋក្រោមទម្រង់ជាស្ថាប័នសាធារណៈ ដែល

មានលក្ខណៈ ឧស្សាហកម្ម និងពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះដែរ ធនាគារសាធារណៈ និងឯកជនជាច្រើនត្រូវបាន បិទ ហើយរាជរដ្ឋាភិបាលបានកសាងធនាគារដែលគ្រប់គ្រងដោយរដ្ឋមួយចំនួនដូចជា ធនាគារឥណទានសម្រាប់ការអភិវឌ្ឍន៍ និងធនាគារកសិកម្មជនបទ។

## របបខ្មែរក្រហម (១៩៧៥-១៩៧៩)

នាថ្ងៃ១៧ ខែមេសាឆ្នាំ១៩៧៥ នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) កាន់អំណាច ធនាគារជាតិនៃកម្ពុជាត្រូវបានបិទទ្វារ អគារស្នាក់ការត្រូវបានកម្ទេច រូបិយវត្ថុ ជាតិត្រូវបានឈប់ប្រើប្រាស់ ហើយប្រព័ន្ធធនាគារត្រូវបានលុបបំបាត់ចោលទាំងស្រុង។ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមត្រូវបានគេផ្តួលរំលំហើយធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ក្នុងនាមជាធនាគារកណ្តាលរបស់ប្រទេសនិងត្រូវបានប្តូរឈ្មោះជា "ធនាគារជាតិនៃប្រជាជន កម្ពុជា" ដោយក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា។ ទោះជាយ៉ាងនេះក្តី ការកសាងធនាគារជាតិនៃកម្ពុជានិងប្រទេសជាតិបន្ទាប់ពីសង្គ្រាម ទើបនឹងបញ្ចប់ភ្លាមនេះ គឺមានការលំបាកយ៉ាងខ្លាំង។ជាមួយនឹងការខិតខំប្រឹងប្រែងជម្នះគ្រប់ឧបសគ្គ ដើម្បីកសាងប្រព័ន្ធធនាគារជាថ្មីឡើងវិញដោយផ្តើមចេញពីចំណុចសូន្យ ឯកឧត្តម ជា ចាន់តូ ទេសរដ្ឋមន្ត្រីនិងជាអភិបាល ធនាគារជាតិនៃកម្ពុជា និងជាអ្នកផ្តួចផ្តើមម្នាក់ក្នុងចំណោមអ្នកផ្តួចផ្តើមកសាងធនាគារជាតិនៃកម្ពុជាដទៃទៀត) ព្រមទាំងបុគ្គលិកមួយចំនួនតូច ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម បានប្តេជ្ញាចិត្តយ៉ាងមុះមុតក្នុងការកសាងធនាគារជាតិនៃកម្ពុជាឡើងវិញ។

របបខ្មែរក្រហមបានបន្សល់ទុកនូវបញ្ហាប្រឈមជាច្រើន។ ដោយសារបញ្ញវន្តជាច្រើនរូប ត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម និងខ្លះទៀតបានភៀសខ្លួនចេញពីប្រទេសបន្ទាប់ពីសង្គ្រាម ចំនួនអ្នកចេះដឹង អ្នកជំនាញ និងអ្នកមានបទពិសោធន៍មានចំនួនតិចតួច។អ្នកនៅរស់រានមានជីវិតនិងមានសមត្ថភាពមួយចំនួន ដែលនៅសេសសល់ក្នុងប្រទេសមានការភ័យ ខ្លាចក្នុងការធ្វើការ ដោយសារពួកគេមានគិតថារបបខ្មែរក្រហមអាចនឹងវិលត្រឡប់មកវិញ។ លើសពីនេះទៀត គឺមានកង្វះយ៉ាងធ្ងន់ធ្ងរនៃធនធានហិរញ្ញវត្ថុ។

ក្នុងពេលដែលសេដ្ឋកិច្ចនៅទន់ខ្សោយនៅឡើយ ហើយការផ្គត់ផ្គង់សាច់ប្រាក់ស្ទើរតែ មិនមានសោះ ដោយសារតែគោលនយោបាយរបស់ខ្មែរក្រហមសកម្មភាពសេដ្ឋកិច្ចនៅតែត្រូវ បានធ្វើឡើងជាលក្ខណៈដោះដូរទំនិញនឹងទំនិញ ចំណែកប្រាក់ខែមន្ត្រីរាជការស៊ីវិលត្រូវបានទូទាត់ដោយប្រើអង្ករ ត្រី ប្រេង ជាដើម។ រហូតដល់ថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៨០ ធនាគារនៃប្រជាជនកម្ពុជាបានបោះផ្សាយប្រាក់រៀលឡើងវិញ ដើម្បីសម្រួលដល់ការដោះដូរទំនិញ និងការទូទាត់ប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល។ បើទោះបីជាជួបប្រទះបញ្ហាប្រឈមទាំងនេះជារៀងរាល់ថ្ងៃខែឆ្នាំក៏ដោយក៏មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជានៅតែបន្តពុះពារឆ្ពោះទៅមុខជានិច្ចក្នុងការកសាងធនាគារជាតិឡើងវិញបន្តិចម្តងៗ។

## ការកសាងធនាគារជាតិនៃកម្ពុជាឡើងវិញ (១៩៧៩-១៩៩៣)

ក្នុងអំឡុងទសវត្សឆ្នាំ១៩៨០ ធនាគារនៃ ប្រជាជនកម្ពុជាមានតួនាទីចម្បងៗបីគឺជា អាជ្ញាធររូបិយវត្ថុជារតនាគារជាតិ និងជាអ្នកផ្តល់សេវាកម្មធនាគារដែលរួមមាន សេវាឥណទាន សេវាទទួលប្រាក់បញ្ញើ និងសេវាទូទាត់ ។ ចាប់តាំងពីអគារស្នាក់ការធនាគារជាតិនៃកម្ពុជា ត្រូវបានកំទេចដោយខ្មែរក្រហម ស្នាក់ការកណ្តាល

បណ្ដោះអាសន្នរបស់ធនាគារ ត្រូវបានបើកនៅជាន់លើនៃធនាគារខ្មែរពាណិជ្ជ។ ធនាគារប្រជាជននៃកម្ពុជា បានបង្កើត រចនាសម្ព័ន្ធដឹកនាំក៏ដូចជាសកម្មភាពប្រតិបត្តិការជាច្រើនទៀត និងបានពង្រីកបណ្ដាញសាខារបស់ខ្លួនដល់ ២៤ ខេត្ត-ក្រុងទូទាំងប្រទេស ។ ចាប់តាំងពីឆ្នាំ១៩៨៩ មក ប្រព័ន្ធធនាគារ បានធ្វើកំណែទម្រង់បន្តិចម្ដងៗ



តាមរយៈការផ្លាស់ប្ដូរធនាគារខេត្ត-ក្រុងចំនួន២០ ទៅជា ធនាគារឯកទេសខេត្ត-ក្រុងហើយធ្វើប្រតិបត្តិការជាមួយនឹងស្វ័យភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនៅក្នុងដែនដីរបស់ពួកគេ។ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារនៃប្រជាជនកម្ពុជាបាន ត្រួតពិនិត្យលើដំណើរការរបស់ធនាគារពាណិជ្ជទាំងនោះ។ អគារស្នាក់ការធនាគារជាតិនៃកម្ពុជាត្រូវបានកសាងឡើងវិញនៅឆ្នាំ ១៩៩០។

នៅឆ្នាំ១៩៩១ ធនាគារពាណិជ្ជដំបូងគេ( ធនាគារពាណិជ្ជកម្ពុជា"CCB" ) ត្រូវបានបង្កើត ឡើងក្រោមទម្រង់ជាធនាគារវិនិយោគរួមគ្នារបស់រដ្ឋដើម្បីទាក់ទាញវិនិយោគិន និងបម្រើឱ្យ សកម្មភាពអាជ្ញាធរអ៊ុនតាក់ប្រចាំនៅកម្ពុជា។ សន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ តុលាឆ្នាំ១៩៩១បានផ្លាស់ប្ដូររបបសេដ្ឋកិច្ចកម្ពុជាពីសេដ្ឋកិច្ចផែនការមកជាសេដ្ឋកិច្ចទីផ្សារសេរី។

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩២ រដ្ឋសភាជាតិបានអនុម័តច្បាប់ស្ដីពីការប្ដូរឈ្មោះ និងកាតព្វកិច្ចរបស់ធនាគារជាតិនៃកម្ពុជាពី " ធនាគារនៃប្រជាជនកម្ពុជា" មកជា "ធនាគារ ជាតិនៃកម្ពុជា" វិញ ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រុមប្រឹក្សារដ្ឋនាថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩២។ ធនាគារជាតិនៃកម្ពុជា បានចងក្រងនិងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យ ហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០។ ឯកសារនេះ មានមុខងារជាមូលដ្ឋានគ្រឹះសម្រាប់យុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដើម្បីបង្កើនទំនុកចិត្តរបស់សាធារណជនចំពោះប្រព័ន្ធធនាគារ និងវិធីសាស្ត្រដែលកម្ពុជាអាចធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសកល ។ ក្នុងនាមជា

ធនាគារកណ្តាលរបស់ជាតិ ធនាគារជាតិនៃកម្ពុជាធ្វើការកែលម្អអគារស្នាក់ការ នៅឆ្នាំ២០០៣ ដើម្បីលើកមុខមាត់ និងកិត្យានុភាពរបស់ខ្លួន។

ប្រព័ន្ធធនាគារនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សំគាល់ ចាប់តាំងពីពាក់កណ្តាល ទសវត្សឆ្នាំ១៩៩០ នៅពេលដែលច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិ នៃកម្ពុជាច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងច្បាប់និងបទប្បញ្ញត្តិនានា ក៏ដូចជាគន្លឹះ នៃការធ្វើកំណែទម្រង់វិស័យធនាគារសំខាន់ផ្សេងទៀតត្រូវបានអនុវត្ត។

**ទំនើបភាវូនីយកម្មប្រព័ន្ធធនាគារ (១៩៩៣-បច្ចុប្បន្ន)**

បច្ចុប្បន្ន ប្រព័ន្ធធនាគារនៅកម្ពុជា រួមមាន ធនាគារពាណិជ្ជចំនួន៣៦ ធនាគារឯកទេស ចំនួន១១ តំណាងធនាគារបរទេសចំនួន៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៣៩ (ក្នុងនោះរួម បញ្ចូលទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៧) ប្រតិបត្តិករឥណទានជនបទ ចំនួន៣៨ ក្រុមហ៊ុនជួលចំនួន៦ ការិយាល័យឥណទានចំនួន១, ដំណើរការតតីយភាគី ចំនួន៦ និងអាជីវករប្តូរប្រាក់ចំនួន១.៧៧០។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបាននិងកំពុងបន្តពង្រីក បណ្តាញប្រតិបត្តិការរបស់ខ្លួន តាមរយៈការបើកសាខា និងការិយាល័យតំណាងជាច្រើនកន្លែងក្នុងរាជធានី-ខេត្ត និងតម្លើងម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ (អេធីអឹម) បន្ថែមលើការ ផ្តល់សេវាទូទាត់អេឡិចត្រូនិក។

**៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់ធនាគារជាតិនៃកម្ពុជា**

**ក. ចក្ខុវិស័យ**

**គោលបំណង**របស់ធនាគារជាតិគឺដើម្បីបង្កើនប្រតិបត្តិការរបស់ធនាគារ សម្រាប់ចូលរួមកសាងជាតិ និងធានាឱ្យប្រជាជនកម្ពុជាទទួលបាននូវសេវាធនាគារពាណិជ្ជដែលមានអត្រាការប្រាក់ប្រកួតប្រជែង និងបង្កើនការសន្សំដើម្បីផ្តល់នូវមូលនិធិឱ្យមានកំណើនសេដ្ឋកិច្ចកាន់តែខ្លាំងនៃប្រទេសកម្ពុជានិងមានសក្តានុពលភាពខ្ពស់ផងដែរ។

**ខ. បេសកកម្ម**

**បេសកកម្ម**បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា គឺការកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍ សេដ្ឋកិច្ចជាតិ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

**គ. គោលដៅ**

**ធនាគារជាតិ**នៃកម្ពុជាមានគោលដៅគឺកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុសំដៅរក្សាស្ថិរភាពថ្លៃ ដើម្បីរួមចំណែកជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន អតិផរណាត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតទាបក្នុងអត្រាមធ្យមប្រចាំឆ្នាំតិចជាង ៥% ដែលសមស្របសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ទោះជាយ៉ាងនេះក្តីក្នុងបរិការណ៍សេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុនៅមានកម្រិតនៅឡើយស្របពេលដែលធនាគារជាតិនៃកម្ពុជាពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដើរតួជាអ្នកឱ្យខ្ចីចុងក្រោយ ។បច្ចុប្បន្ន ឧបករណ៍គោលនយោបាយរូបិយវត្ថុដែលត្រូវបានប្រើប្រាស់ដើម្បីរក្សាស្ថិរភាពថ្លៃ គឺការដាក់អត្រាប្រាក់បម្រុងកាតព្វកិច្ច និងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍន៍ ឧបករណ៍គោលនយោបាយរូបិយវត្ថុបន្ថែម ដើម្បីពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ តាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន ការអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុ និងការពង្រឹងការប្រើប្រាស់ប្រាក់រៀល។

## ៣.១.៣ រចនាសម្ព័ន្ធ ធនាគារជាតិនៃកម្ពុជា



## ៣.២ នីតិវិធីក្នុងការប្រើប្រាស់ប្រាក់រៀលឱ្យមានប្រសិទ្ធភាពរបស់ធនាគារជាតិនៃកម្ពុជា

### ៣.២.១ គោលនយោបាយអត្រាប្តូរប្រាក់

គោលនយោបាយអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា គឺជាឧបករណ៍នយោបាយមួយរបស់គោលនយោបាយរូបិយវត្ថុដែលមានគោលដៅចម្បងរក្សាស្ថិរភាពថ្លៃ។ ជាមួយនឹងការអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ធនាគារជាតិនឹងធ្វើអន្តរាគមលើទីផ្សារប្តូរប្រាក់ ដើម្បីគ្រប់គ្រងនិងរក្សាស្ថិរភាព អត្រាប្តូរប្រាក់ទៅតាមគោលដៅដែលបានកំណត់។ អត្រាប្តូរប្រាក់ផ្លូវការ ជាអត្រាទិញ-លក់រវាងរូបិយវត្ថុជាតិ និងរូបិយប័ណ្ណបរទេសផ្សេងទៀត។អត្រាប្តូរប្រាក់ផ្លូវការនេះត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា និងដាក់ឱ្យប្រើប្រាស់សម្រាប់រាល់ប្រតិបត្តិការ រវាងធនាគារជាតិនៃកម្ពុជាជាមួយនឹងភាគីពាក់ព័ន្ធ។លើសពីនេះក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជា សាធារណៈជនអាចប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការនេះទៅតាមគោលដៅរៀងៗខ្លួន ហើយអត្រានេះក៏ជា អត្រាប្តូរប្រាក់គោលប្រើដោយវិស័យឯកជនផងដែរ ។

### ៣.២.២ គោលនយោបាយប្រាក់បម្រុងកាតព្វកិច្ច

ប្រាក់បម្រុងកាតព្វកិច្ចជាឧបករណ៍គោលនយោបាយរូបិយវត្ថុមួយ ដែលធនាគារជាតិនៃកម្ពុជាប្រើដើម្បីគ្រប់គ្រងល្បឿនកំណើនឥណទាន។ បច្ចុប្បន្ន អត្រាប្រាក់បម្រុងកាតព្វកិច្ចសម្រាប់រូបិយប័ណ្ណបរទេស (ជាពិសេស ប្រាក់ដុល្លារអាមេរិក) និងរូបិយវត្ថុជាតិ ត្រូវបានកំណត់ផ្សេងគ្នា។អត្រាប្រាក់បម្រុងកាតព្វកិច្ចសម្រាប់រូបិយបណ្ណបរទេស និងរូបិយវត្ថុជាតិ ត្រូវបានកំណត់ក្នុងអត្រា១២.៥% និង៨% រៀងគ្នា។ ចំពោះប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេសចំនួន ១២.៥% ក្នុងនោះ ៤.៥% ត្រូវបានផ្តល់ការប្រាក់ដោយធនាគារជាតិនៃកម្ពុជា និង៨% បន្ថែមទៀតមិនត្រូវបានផ្តល់ការប្រាក់ទេ។ ចំពោះប្រាក់បម្រុងកាតព្វកិច្ចជារៀលក៏មិនត្រូវបានផ្តល់ការប្រាក់ដែរ។

### ៣.២.៣ ការគ្រប់គ្រងការផ្គត់ផ្គង់សាច់ប្រាក់

ដោយសារកម្ពុជា ជាប្រទេសដែលមានកម្រិតដុល្លាររូបនីយកម្មខ្ពស់ ឧបករណ៍ទូទាត់សងប្រាក់ភាគច្រើនត្រូវធ្វើឡើងជាពីររូបិយប័ណ្ណ គឺជារូបិយវត្ថុរៀល (KHR) និងជាដុល្លារអាមេរិក (USD) ។ ទោះជាយ៉ាងណាក៏ដោយប្រតិបត្តិការទូទាត់សងប្រាក់ជារូបិយប័ណ្ណដុល្លារអាមេរិកមានទំហំធំជាងប្រតិបត្តិការទូទាត់សងប្រាក់ជារៀល។ ការប្រើប្រាស់ឧបករណ៍ទូទាត់សងប្រាក់ ដែលមិនមែនជាសាច់ប្រាក់នៅកម្ពុជាសម្រាប់ប្រតិបត្តិការទូទាត់អន្តរធនាគារ នៅមានកម្រិតដោយសារពុំមានសេវាទូទាត់សងប្រាក់ជាអេឡិចត្រូនិកដែលអាចទទួលយកបានទូលំទូលាយ។

#### សាច់ប្រាក់

ប្រទេសកម្ពុជាជាប្រទេសមួយដែលប្រើប្រាស់សាច់ប្រាក់ខ្ពស់ដោយសារតែសាច់ប្រាក់ត្រូវបានគេចាត់ទុកថាជាមធ្យោបាយទូទាត់សងប្រាក់ដែលងាយស្រួលនិងមានប្រជាប្រិយភាព។ ដោយសារតែកម្រិតដុល្លាររូបនីយកម្មខ្ពស់ រូបិយប័ណ្ណដុល្លារអាមេរិកត្រូវបានគេទទួលយកយ៉ាងទូលំទូលាយជំនួសឱ្យរូបិយវត្ថុរៀល។ បច្ចុប្បន្ន មានប្រភេទរូបិយវត្ថុចំនួនដប់ប្រភេទនៅក្នុងចរាចរណ៍ គឺប្រភេទ ១០០.០០០ រៀល ៥០.០០០ ២០.០០០ ១០.០០០ ៥.០០០ ២.០០០ ១.០០០ ៥០០ និង១០០ រៀល។ ចំណែកកាសពុំពេញនិយមសម្រាប់ការប្រើប្រាស់ឡើយ។

**៣.២.៤ កាត់បន្ថយចំណាយប្រតិបត្តិការ**

ការប្រើប្រាស់រូបិយប័ណ្ណលើសពីមួយនៅក្នុងសេដ្ឋកិច្ច បានបង្កើនចំណាយប្រតិបត្តិការ ទាំងពេលវេលា និង ប្រាក់កាស។ ទំនិញនិងសេវាអាចនឹងត្រូវបានគិតថ្លៃជារូបិយប័ណ្ណផ្សេងៗគ្នា អាស្រ័យលើ ៖ ក) ប្រភពដើម នៃទំនិញ និងសេវាទាំងនោះ (ផលិតក្នុងស្រុក ឬនាំចូល) ខ)ទំហំប្រតិបត្តិការ (តូច ឬធំ) គ) និងប្រភេទទីផ្សារ (ប្រពៃណី ឬទំនើប) ។ ដោយសារតែប្រាក់រៀលនិងដុល្លារអាមេរិកចរាចរទន្ទឹមគ្នាអ្នកទិញប្រឈមនឹងការខាតបង់ អាស្រ័យលើប្រាក់ ដែលគេកាន់។ អត្រាប្តូរប្រាក់ត្រូវបានកំណត់ដោយអ្នកលក់ ដោយមិនផ្អែកលើអត្រាទីផ្សារ និង មានទំនោរផ្តល់អត្ថប្រយោជន៍ដល់អ្នកលក់។ ឧទាហរណ៍៖ អ្នកទិញត្រូវប្តូរប្រាក់មុននឹងទូទាត់ឱ្យអ្នកលក់ដែលធ្វើឱ្យខាតទាំងពេលវេលានិងប្រាក់កាស។ អ្នកលក់ក៏ខាតទាំងពេលវេលានិងប្រាក់កាសផងដែរ នៅពេលដែលពួកគេកំណត់ថ្លៃទំនិញជា រូបិយប័ណ្ណផ្សេងៗគ្នា។ អ្នកលក់ប្រឈមនឹងផលលំបាកចំពោះការធ្វើកិច្ចបញ្ជីកាគណនេយ្យ នៅពេលដែលរូបិយវត្ថុ/រូបិយប័ណ្ណដែលគេទទួលបានខុសពីរូបិយវត្ថុ រូបិយប័ណ្ណដែលគេប្រើប្រាស់ក្នុងប្រព័ន្ធគណនេយ្យ។ទាំងអ្នកលក់ និងអ្នកទិញ សុទ្ធតែប្រឈមនឹងហានិភ័យអត្រាប្តូរប្រាក់ នៅពេលដែលតម្លៃនៃរូបិយវត្ថុ និងរូបិយប័ណ្ណប្រែប្រួល។

ការប្រើប្រាស់រូបិយវត្ថុជាតិតែមួយចំពោះការទូទាត់គ្រប់ប្រតិបត្តិការនៅក្នុងសេដ្ឋកិច្ចជាតិនឹងអាចជួយកាត់បន្ថយចំណាយជាច្រើនសម្រាប់អ្នកលក់និងអ្នកទិញ។ លើសពីនេះការប្រើប្រាស់នេះនឹងអាចជួយបង្កើនប្រតិបត្តិការសេដ្ឋកិច្ច កាន់តែច្រើន ដោយសារភាពងាយស្រួលឆាប់រហ័ស និងមានប្រសិទ្ធភាពនៅពេលដែលភាគីទាំងពីរមិនចាំបាច់ត្រូវខ្វល់ ពីប្រភេទរូបិយវត្ថុ រូបិយប័ណ្ណក្នុងការទូទាត់ ឬគម្លាតអត្រាប្តូរប្រាក់ទេ។

**៣.២.៥ រក្សាស្ថិរភាពថ្លៃ**

តាមទ្រឹស្តី ស្ថិរភាពថ្លៃត្រូវបានរក្សាតាមរយៈការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច។ ដូចគ្នាទៅនឹងទំនិញដែរការផ្គត់ផ្គង់រូបិយវត្ថុលើសទៅក្នុងចរាចរណ៍សេដ្ឋកិច្ចនឹងធ្វើឱ្យតម្លៃរូបិយវត្ថុថយចុះ ហើយក៏នឹងធ្វើឱ្យសម្ពាធអតិផរណាកើនឡើងផងដែរ។ ផ្ទុយទៅវិញប្រសិនបើការផ្គត់ផ្គង់ទាបជាងតម្រូវការនោះនឹងធ្វើឱ្យរូបិយវត្ថុឡើងថ្លៃខ្ពស់ជាងកម្រិតសមស្រប ដែលអាចធ្វើឱ្យមានបរិត្តផរណា (ការធ្លាក់ថ្លៃទំនិញ)។ ដូច្នេះ ទាំងការផ្គត់ផ្គង់លើស និងខ្វះ សុទ្ធតែមានផលប៉ះពាល់ដល់តម្លៃទំនិញនៅលើទីផ្សារ។

អតិផរណាខ្ពស់ នឹងផ្តល់ផលប៉ះពាល់អវិជ្ជមានដល់ជីវភាពរស់នៅរបស់ប្រជាជននៅពេលដែលទំនិញកាន់តែឡើងថ្លៃ ខណៈដែលបរិត្តផរណាក៏នឹងមានផលអវិជ្ជមានចំពោះវិនិយោគិនផងដែរ ដោយសារតែផលចំណេញពីការវិនិយោគមានការថយចុះ។ ប្រសិនបើការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានធ្វើឡើងមិនសមស្រប នោះអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចអាចនឹងកើតឡើងបាន។

ដើម្បីរក្សាស្ថិរភាពថ្លៃធនាគារជាតិនៃកម្ពុជាចាំបាច់ត្រូវគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុដោយស្រូបយក ឬចាក់បញ្ចូលរូបិយវត្ថុទៅក្នុងទីផ្សារ។ នៅកម្ពុជាដោយសារតែដុល្លារូបនីយកម្មមានកម្រិតខ្ពស់ហើយរូបិយប័ណ្ណបរទេសមានការចរាចរដោយសេរី (ប្រការនេះលើសពីដែនសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជា) ធនាគារជាតិនៃកម្ពុជាមិនអាចកំណត់ពីចំនួនប្រាក់ដុល្លារអាមេរិក និងរូបិយប័ណ្ណផ្សេងៗទៀតដែលកំពុងចរាចរណ៍នៅក្នុងសេដ្ឋកិច្ចបានទេ។ដូច្នេះប្រសិទ្ធភាពនៃការអនុវត្ត គោលនយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាពថ្លៃក៏ត្រូវបានដាក់កំហិតផងដែរ។

### ៣.២.៦ ជំរុញពាណិជ្ជកម្ម

នាពេលបច្ចុប្បន្ន កម្ពុជាពឹងផ្អែកមួយភាគធំទៅលើការនាំចេញនិងទេសចរណ៍ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចរបស់ខ្លួន។ ប្រសិនបើកម្ពុជាប្រើប្រាស់តែប្រាក់រៀលនោះធនាគារជាតិនៃកម្ពុជាអាចជំរុញការនាំចេញដោយធ្វើឱ្យភាពប្រកួតប្រជែងថ្លៃកើនឡើងតាមរយៈការបន្ថយតម្លៃរូបិយវត្ថុ។ ដូច្នេះការបន្ថយតម្លៃរូបិយវត្ថុនឹងធ្វើឱ្យការនាំចេញកើនឡើង។

អំណាចនៃការបន្ថយតម្លៃរូបិយវត្ថុ គឺជាសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជាដោយមាន ការប្រឹក្សាជាមួយរាជរដ្ឋាភិបាល និងភាគីតាក់តែងគោលនយោបាយពាក់ព័ន្ធនានា ។ ឧទាហរណ៍៖ ដើម្បីផលិតបានអាវ១ គេត្រូវចំណាយប្រាក់ចំនួន៤.០០០រៀល។ ប្រសិនបើអត្រាការប្រាក់ស្ថិតនៅ ក្នុងកម្រិត៤.០០០រៀលក្នុង១ដុល្លារអាមេរិក នោះដៃគូពាណិជ្ជកម្មនឹងត្រូវការប្រាក់១ដុល្លារអាមេរិក ដើម្បីទិញអាវនេះ។ ប៉ុន្តែ ប្រសិនបើប្រាក់រៀលធ្លាក់ដល់៤.២០០រៀល ក្នុង១ដុល្លារអាមេរិក អ្នក នាំចេញនឹងត្រូវការប្រាក់ត្រឹមតែ ០,៨៨ដុល្លារអាមេរិកប៉ុណ្ណោះដើម្បីទិញអាវនេះ ដែលមានន័យថា អាវនេះមានតម្លៃទាបជាងមុននៅលើទីផ្សារអន្តរជាតិ។ នៅពេលតម្លៃទំនិញកាន់តែទាបអ្នកប្រើប្រាស់អាចទិញកាន់តែច្រើនដែលនាំឱ្យតម្រូវការកាន់តែកើនឡើងក៏ដូចជាការបង្កើតការងារកាន់តែច្រើននៅក្នុងប្រទេសផងដែរ។ ដោយសារធាតុចូលនៅក្នុងផលិតកម្ម ដូចជាវត្ថុធាតុដើម និងប្រាក់ឈ្នួលត្រូវបានគិតជាប្រាក់ដុល្លារអាមេរិក ការធ្លាក់ថ្លៃនៃប្រាក់រៀលនឹងមិនមានឥទ្ធិពលលើថ្លៃទំនិញនាំចេញនោះទេដែលនឹងបណ្តាលឱ្យកម្ពុជាបាត់បង់ឱកាសក្នុងការជំរុញការនាំចេញ និងកំណើនសេដ្ឋកិច្ចថែមទៀតផង។ស្រដៀងគ្នានេះដែរ ការធ្លាក់ចុះនៃតម្លៃរូបិយវត្ថុអាចទាក់ទាញភ្ញៀវទេសចរណ៍ច្រើនជាងមុនមកកាន់ប្រទេសកម្ពុជា ដោយសារទំនិញកម្ពុជាមានតម្លៃទាបជាងមុនបើគិតជារូបិយប័ណ្ណ។

### ៣.២.៧ ជំរុញការវិនិយោគ និងការបង្កើតការងារ

ធនាគារកណ្តាលជាច្រើន ដូចជាធនាគារកណ្តាលអាមេរិក បានកែតម្រូវអត្រាការប្រាក់គោលរបស់ខ្លួនដើម្បីជំរុញការវិនិយោគក្នុងស្រុកនិងបង្កើតការងារបន្ថែម។កម្រិតអត្រាការប្រាក់គោលដែលកំណត់ដោយធនាគារកណ្តាលមានឥទ្ធិពលលើថ្លៃដើមនៃមូលនិធិវិនិយោគ គ្រឹះស្ថានធនាគារ ហើយជាលទ្ធផលក៏នាំឱ្យមានការប្រែប្រួលដល់អត្រាការប្រាក់ដែលគ្រឹះស្ថាន ធនាគារកំណត់លើកម្ចីទៅកាន់វិនិយោគិននិងអង្គភាពគ្រួសារផងដែរ។ នៅពេលដែលធនាគារកណ្តាល បន្ទាបការប្រាក់គោល វាជាសញ្ញាណដល់គ្រឹះស្ថានធនាគារក្នុងការកាត់បន្ថយអត្រាការ ប្រាក់កម្ចីដែលនឹងត្រូវធ្វើឱ្យកម្ចីមានតម្រូវការខ្ពស់ជាងមុនសម្រាប់វិនិយោគិននិងអង្គភាពគ្រួសារ។

ធនាគារកណ្តាលក៏អាចដំឡើងអត្រាការប្រាក់គោលផងដែរ ប្រសិនបើមានសញ្ញាណថា បរិមាណកម្ចីមានកំណើនខ្ពស់ហួសហេតុនៅក្នុងសេដ្ឋកិច្ចជាពិសេសនៅក្នុងវិស័យណាមួយ( ឧទាហរណ៍៖ វិស័យសំណង់ និងអចលនទ្រព្យ ) ដើម្បីជៀសវាងការឡើងថ្លៃជ្រុល។ ទ្រឹស្តីនេះអាច អនុវត្តបានតែក្នុងសេដ្ឋកិច្ចដែលប្រើប្រាស់រូបិយវត្ថុក្នុងស្រុកទាំងស្រុងឬមួយភាគធំប៉ុណ្ណោះ។ នៅក្នុងករណីប្រទេសកម្ពុជា ប្រាក់បញ្ញើនិងឥណទានប្រមាណ៩០% គឺជាប្រាក់ដុល្លារអាមេរិក។ ផ្ទុយទៅវិញ ធនាគារជាតិនៃកម្ពុជាអាចផ្តល់តែកម្ចីជាប្រាក់រៀលប៉ុណ្ណោះដល់គ្រឹះស្ថានធនាគារ។ នេះមានន័យថា អត្រាការប្រាក់គោលដែលធនាគារជាតិនៃកម្ពុជាកំណត់ នឹងមិនមានឥទ្ធិពលលើថ្លៃដើមនៃមូលនិធិវិនិយោគរបស់គ្រឹះស្ថានធនាគារនោះទេ។ចំណុចនេះគឺជាគុណវិបត្តិ

ដ៏ធំមួយ សម្រាប់ប្រជាជនកម្ពុជានិងវិនិយោគិន ដែលកំពុងប្រឈមនឹងការចំណាយថ្លៃដើមវិនិយោគខ្ពស់ ដោយសារធនាគារកណ្តាលមិនអាចមានឥទ្ធិពលលើអត្រាការប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារ។

**៣.២.៨ បញ្ហាការក្លែងក្រដាសប្រាក់**

ដោយសារសេដ្ឋកិច្ចកម្ពុជាប្រើប្រាស់ក្រដាសប្រាក់ជាមូលដ្ឋាន ជាពិសេសការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកយ៉ាងទូលំទូលាយ កម្ពុជាអាចជាគោលដៅនៃការហូរចូលក្រដាសប្រាក់ដុល្លារក្លែងក្លាយ ដោយសារតែសាធារណជនមិនសូវមានការយល់ដឹងច្បាស់ពីរូបិយប័ណ្ណបរទេសនិង មិនអាចបែងចែករវាងក្រដាសប្រាក់ពិតនិងក្លែងក្លាយដូចជាតាមរយៈរូបភាពនិងលក្ខណៈនៃ ក្រដាសប្រាក់រូបិយប័ណ្ណបរទេស។ ក្នុងបរិការណ៍នេះ ការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ប្រាក់រៀលកាន់តែទូលំទូលាយ មានសារសំខាន់ណាស់ក្នុងការទប់ស្កាត់ការចរាចររូបិយប័ណ្ណក្លែងក្លាយនៅប្រទេសកម្ពុជា ហើយក៏រួមចំណែកកាត់បន្ថយកម្រិតដុល្លារូបនីយកម្មបន្តិចម្តងៗផងដែរ។

ការប្រើប្រាស់រូបិយវត្ថុជាតិដែលប្រជាជនស្គាល់ច្បាស់ នឹងអាចជួយកាត់បន្ថយនិងបង្ការ ការក្លែងក្រដាសប្រាក់រូបិយប័ណ្ណបរទេសដោយសារតែរូបិយប័ណ្ណទាំងនេះ នឹងហូរចូលទៅក្នុងសេដ្ឋកិច្ចតាមរយៈប្រព័ន្ធធនាគារ។

## ៣.៣ ការប្រើប្រាស់ប្រាក់រៀលជួយលើកស្ទួយដល់សេដ្ឋកិច្ចជាតិ

**៣.៣.១ មោទនភាពជាតិ និងសាមគ្គីភាពជាតិ**

បណ្តាលប្រទេសនីមួយៗតែងតែមាននូវរូបិយវត្ថុជាតិរបស់ខ្លួនដែលតំណាងឱ្យអត្តសញ្ញាណជាតិមាតុភូមិ។ វត្តមាននៃរូបិយវត្ថុជាតិគឺជាមោទនភាពសម្រាប់ប្រជាជនទាំងអស់នៅក្នុងប្រទេស។ ដោយសារតែរូបិយវត្ថុត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងសង្គមមួយចរាចរណ៍ក្រដាសប្រាក់ក្នុង ចំណោមប្រជាជនគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការរំលឹកនិងបង្កើនចំណេះដឹងដល់សាធារណជនអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនិងវប្បធម៌ក៏ដូចជាស្ថានភាពសង្គមនិងសេដ្ឋកិច្ចរបស់ ប្រទេសមួយផងដែរ។ ចំពោះកម្ពុជាក្រដាសប្រាក់រៀលអាចរំលឹកដល់ប្រជាជនពីវីរបុរសដែលមានកិត្តិនាមជាប្រវត្តិសាស្ត្រ(ឧទាហរណ៍ដូចជា ព្រះមហាក្សត្រ) ឬប្រាង្គប្រាសាទនានាដែលត្រូវបានបង្ហាញនៅលើក្រដាសប្រាក់។

ជាមួយការប្រើប្រាស់រូបិយវត្ថុជាតិយើងអាចចូលរួមក្នុងការរក្សាពង្រីកនិងចែករំលែកនូវចំណេះដឹងពីប្រវត្តិសាស្ត្រ វប្បធម៌ និងអត្តសញ្ញាណជាតិដល់អ្នកជំនាន់ក្រោយហើយនឹងអាចពង្រឹងនូវស្មារតីបង្រួបបង្រួមជាតិក្នុងនាមជាប្រជាជននៅក្នុងសង្គមនិងជាតិតែមួយ។

**៣.៣.២ គោលនយោបាយសារពើពន្ធ**

គោលនយោបាយសារពើពន្ធ ប្រៀបបានដូចជាស្នូលនៃការជំរុញការប្រើប្រាស់រូបិយវត្ថុរបស់ភ្នាក់ងារសេដ្ឋកិច្ចទាំងអស់ ដោយសារការទទួលស្គាល់និងប្រើប្រាស់រូបិយវត្ថុនៃប្រទេសមួយគឺចាំបាច់ត្រូវមានការគាំទ្ររបស់រាជរដ្ឋាភិបាល។ តាមរយៈការគ្រប់គ្រងចំណូលនិងចំណាយរបស់ខ្លួនរដ្ឋាភិបាលនឹងបង្កើនចរន្តនៃលំហូររូបិយវត្ថុឱ្យកាន់តែសកម្មដែលក្នុងពេលជំណាលគ្នានោះ នឹងបង្កើនទាំងតម្រូវការនិងផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច។ ដូចនេះការកំណត់ និងការទូទាត់ជារូបិយវត្ថុជាតិនៅក្នុងគ្រប់ប្រតិបត្តិការចំណូលចំណាយរបស់រដ្ឋរាប់តាំងពីចំណាយ ឬចំណូលតូចតាច រហូតដល់ទំហំធំនៅក្នុងស្រុកលើគ្រប់ទិដ្ឋភាពមានសារសំខាន់ណាស់នៅក្នុងការរួមចំណែកដោយផ្ទាល់ដល់ការលើកកម្ពស់ការគាំទ្រ និងប្រើប្រាស់រូបិយវត្ថុជាតិ។

រាជរដ្ឋាភិបាលគួរផ្តោតការយកចិត្តទុកដាក់លើការកាត់បន្ថយឱនភាពថវិកាតាមរយៈការធ្វើវិចារណកម្មចំណាយព្រមទាំងពង្រឹងមូលដ្ឋានពន្ធនិងបង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធនៅក្នុងប្រទេស។ ឱនភាពថវិកាមានកម្រិតទាបនឹងអនុញ្ញាតឱ្យរដ្ឋាភិបាលគ្រប់គ្រងបំណុលបានល្អប្រសើរនិងពង្រឹងជំនឿទុកចិត្តរបស់ភ្នាក់ងារសេដ្ឋកិច្ចមកលើស្ថាប័នសាធារណៈនិងរូបិយវត្ថុជាតិ។ ជាមួយគ្នានេះរដ្ឋាភិបាលនឹងប្រមូលផ្តុំចំណូលថវិកាជាតិជារូបិយប័ណ្ណចូលទៅក្នុងធនាគារជាតិនៃកម្ពុជាដោយអនុវត្តក្រោមរូបភាពជាប្រាក់បញ្ញើ ឬលក់ជូនធនាគារជាតិនៃកម្ពុជា។ការប្រមូលផ្តុំរូបិយប័ណ្ណចូលទៅក្នុងធនាគារជាតិនៃកម្ពុជា នឹងបង្កលក្ខណៈងាយស្រួលផងដែរដល់រដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណូលជារូបិយប័ណ្ណ និងធ្វើការប្តូរជារូបិយវត្ថុបានគ្រប់ពេលវេលាតាមតម្រូវការ។នៅក្នុងករណីដែលត្រូវការហិរញ្ញប្បទានថវិកាជាតិរដ្ឋាភិបាលនឹងបោះផ្សាយមូលបត្របំណុលរបស់រដ្ឋជារូបិយវត្ថុជាតិ និងជៀសវាងការបោះផ្សាយនូវរាល់ឧបករណ៍បំណុលជារូបិយប័ណ្ណ។

ម៉្យាងវិញទៀតប្រទេសជាច្រើនដែលទទួលបានជោគជ័យក្នុងការបង្កើនតួនាទីរូបិយវត្ថុជាតិបានខិតខំធានាថា បន្ទុកពន្ធជាក់ស្តែង (effective tax) នៅលើទ្រព្យសកម្ម និងអកម្មដែលចារឹកជារូបិយវត្ថុក្នុងស្រុកមិនខ្ពស់ជាងបន្ទុកពន្ធនៅលើទ្រព្យសកម្ម និងទ្រព្យអកម្មដែលចារឹកជារូបិយប័ណ្ណបរទេសឡើយ។ នៅក្នុងករណីខ្លះទៀតឧបករណ៍ចារឹកជារូបិយប័ណ្ណត្រូវរងបន្ទុកពន្ធធ្ងន់ធ្ងរជាងឧបករណ៍ចារឹកជារូបិយវត្ថុជាតិ។ ឧទាហរណ៍ការដាក់ពន្ធលើប្រាក់ចំណូល ឬចំណេញជាប្រាក់រៀលដែលទទួលបានមកពីសកម្មភាពសេដ្ឋកិច្ចនានា ឬប្រាក់បញ្ញើជារៀលក្នុងប្រព័ន្ធធនាគារ ឬការផ្ទេរនានាជាប្រាក់រៀលជាដើមនឹងត្រូវលើកទឹកចិត្តតាមរយៈការដាក់កម្រិតអត្រាពន្ធពិតមួយដែលអំណោយផលដល់រូបិយវត្ថុជាតិ។

**៣.៣.៣ គោលនយោបាយពាណិជ្ជកម្ម**

រូបិយវត្ថុគឺជាប្រេងរំអិលនៃសកម្មភាពពាណិជ្ជកម្មទន្ទឹមនេះការរីកចម្រើននៃសកម្មភាពពាណិជ្ជកម្មក៏ជាកត្តាដែលបង្កើនតម្រូវការរូបិយវត្ថុដែរ។ ដូច្នេះការផ្សារភ្ជាប់គោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងគោលនយោបាយពាណិជ្ជកម្មមានសារៈសំខាន់ខ្លាំងណាស់ដើម្បីរក្សានិរន្តរភាពនៃការប្រើប្រាស់ប្រាក់រៀលដោយភ្នាក់ងារសេដ្ឋកិច្ចក្នុងសកម្មភាពដោះដូររបស់ខ្លួន។

រដ្ឋាភិបាលគួរកាត់បន្ថយឱនភាពពាណិជ្ជកម្មតាមរយៈការពង្រឹងការនាំចេញនិងកាត់បន្ថយការនាំចូល។ ការបង្កើនការនាំចេញនឹងត្រូវគាំទ្រដោយការបង្កើនផលិតភាពនៃផលិតកម្មពង្រីកនិងពិពិធកម្មទាំងទីផ្សារ និងផលិតផលដែលផលិតក្នុងស្រុក។ ការបង្កើនផលិតកម្មក្នុងស្រុកមិនត្រឹមតែនឹងបង្កើនតម្រូវការរូបិយវត្ថុនៅក្នុងការដោះដូរផលិតផលទាំងនេះទេតែថែមទាំងជួយកាត់បន្ថយការនាំចូលដូច្នេះបន្ថយតម្រូវការរូបិយប័ណ្ណ។ កន្លងមករាជរដ្ឋាភិបាលបានខិតខំធ្វើពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និងជំរុញការធ្វើពិពិធកម្មការនាំចេញ។រាជរដ្ឋាភិបាលគួរបន្តអនុវត្តគោលនយោបាយនេះថែមទៀត និងបន្តជួយគាំទ្រការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ។ រដ្ឋាភិបាលក៏បានដាក់ឱ្យអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មដែលជំរុញឱ្យមានការរីកដុះដាលនៃសហគ្រាសធុនតូចនិងមធ្យម និងផលិតកម្មក្នុងស្រុកដែលទាំងនេះនឹងរួមចំណែកកាត់បន្ថយឱនភាពជញ្ជីងពាណិជ្ជកម្មផងដែរ។ លើសពីនេះរដ្ឋាភិបាលគួរបន្តគាំទ្រដល់ការបង្កើនផលិតភាពលើផលិតកម្មនានាតាមរយៈការអភិវឌ្ឍបច្ចេកទេសនិងជំនាញនានាឱ្យកាន់តែប្រសើរឡើងដើម្បីបង្កើនផលិតកម្មក្នុងស្រុក។ ទន្ទឹមនេះការជំរុញផលិតកម្មវិស័យកសិកម្មក៏នឹងរួមចំណែកដោយផ្ទាល់ដល់ការកាត់បន្ថយការនាំចូលទំនិញកសិកម្មពី

បរទេសជាពិសេសប្រទេសជិតខាង និងបង្កើនតម្រូវការប្រាក់រៀលដោយសារប្រាក់រៀលត្រូវប្រើប្រាស់លើសលុបនៅក្នុងវិស័យកសិកម្ម។ ទាក់ទងនឹងវិស័យសេវាកម្មកម្ពុជា មានឧត្តមភាពខ្ពស់ដោយសារចំណូលដុល្លពីវិស័យសេវាកម្មមានអតិរេកដែលគាំទ្រដោយវិស័យទេសចរ។ កន្លងមកការទទួលបានរូបិយប័ណ្ណពីទេសចរត្រូវបានប្រើប្រាស់បន្តដោយគ្មានការប្តូរប្រាក់ទៅជារូបិយវត្ថុជាតិទេ។ ក្នុងបរិការណ៍នេះធនាគារជាតិនៃកម្ពុជាក៏ដូចជាអាជ្ញាធរពាក់ព័ន្ធដូចជា ក្រសួងទេសចរណ៍ និងអាជ្ញាធរមានសមត្ថកិច្ចគឺបង្កើនការប្រើប្រាស់ប្រាក់រៀលរបស់ភ្ញៀវទេសចរ និងស្រូបយករូបិយប័ណ្ណដែលទទួលបានទៅក្នុងប្រព័ន្ធធនាគារ។ ចំពោះការដោះដូរក្នុងស្រុកការកំណត់យករូបិយវត្ថុជាតិជាឯកតាកំណត់ និងតាំងថ្លៃ និងជាមធ្យោបាយទូទាត់ នឹងបង្កើនការប្រើប្រាស់ប្រាក់រៀលដោយផ្ទាល់នៅក្នុងសេដ្ឋកិច្ច ហើយបន្ទាប់មកនឹងអាចមានឥទ្ធិពលវិជ្ជមានដល់ការប្រើប្រាស់ប្រាក់រៀលដោយផ្ទាល់នៅក្នុងវិស័យហិរញ្ញវត្ថុថែមទៀត។

រដ្ឋាភិបាលគួរលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែមានភាពទូលំទូលាយជាឯកតាកំណត់ និងដាក់តាំងថ្លៃ។ ការជំរុញមុខងាររបស់ប្រាក់រៀលជាឯកតាកំណត់ និងដាក់តាំងថ្លៃគួរត្រូវអនុវត្តនៅក្នុងផ្នែក ឬវិស័យជាក់លាក់មួយចំនួនបន្ទាប់មកអាចនឹងជំរុញឬពង្រីកបន្ថែមទៀតនៅក្នុងផ្នែក ឬវិស័យជាក់លាក់ដទៃទៀត។ យោងតាមទ្រឹស្តី និងបទពិសោធន៍អន្តរជាតិវិធានការបែបនេះមានផលប៉ះពាល់តិចតួចបំផុតចំពោះទំនុកចិត្តរបស់សាធារណជន និងដំណើរការសេដ្ឋកិច្ច។ ជំហាននេះក៏ជាមូលដ្ឋានគ្រឹះដ៏សំខាន់ផងដែរចំពោះការលើកកម្ពស់តួនាទីប្រាក់រៀលជាមធ្យោបាយទូទាត់។ ប្រសិនបើមិនមានវឌ្ឍនភាពសម្រាប់ការដាក់ឱ្យប្រើប្រាស់ប្រាក់រៀលសម្រាប់ការកំណត់ និងការដាក់តាំងថ្លៃទំនិញ និងសេវាឱ្យបានទូលំទូលាយទេនោះការលើកស្ទួយប្រាក់រៀលជាមធ្យោបាយទូទាត់យ៉ាងទូលំទូលាយនឹងនៅតែមានកម្រិត។

ដើម្បីឱ្យការអនុវត្តនេះប្រព្រឹត្តទៅដោយប្រសិទ្ធភាពអាជ្ញាធរចាំបាច់ត្រូវអនុញ្ញាតឱ្យមានរយៈពេលអន្តរកាលមួយ (ឧទាហរណ៍ប្រមាណ១ឆ្នាំ ឬ២ឆ្នាំ)សម្រាប់ត្រៀមលក្ខណៈផ្លាស់ប្តូរពីការកំណត់និងការដាក់តាំងថ្លៃជាប្រាក់ដុល្លារមកជាប្រាក់រៀលវិញ។ ក្នុងអំឡុងពេលអន្តរកាលនេះ ផ្អែកលើការស្ម័គ្រចិត្តរបស់វិស័យឯកជន ថ្លៃទំនិញអាចបន្តដាក់តាំងជាប្រាក់ដុល្លារដែលនឹងជួយ សម្រួលជាបណ្តើរៗ ចំពោះពាណិជ្ជករក្នុងការរៀបចំចាត់ចែងដាក់ថ្លៃថ្មីទៅលើទំនិញរបស់ពួកគេ។ បន្ទាប់ពីដំណាក់កាលនេះថ្លៃទំនិញទាំងអស់ត្រូវឈប់បង្ហាញជារូបិយប័ណ្ណ។ ក្នុងរយៈពេលខ្លីទោមធ្យមប្រាក់បៀវត្សរ៍ក៏ត្រូវចារឹកជាប្រាក់រៀលដែរ។ ប៉ុន្តែក្នុងអំឡុងពេលអន្តរកាលមួយដោយឡែកប្រាក់បៀវត្សរ៍អាចត្រូវបានលើកលែងឱ្យបន្តកំណត់ជាប្រាក់ដុល្លារដើម្បីឱ្យនិយោជក និងធនាគារមានពេលវេលាសម្រាប់កែប្រែការចុះកិច្ចបញ្ជីកាក្នុងគណនេយ្យរបស់ខ្លួន។

រដ្ឋាភិបាលគួរលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែមានភាពទូលំទូលាយជាមធ្យោបាយទូទាត់។ នៅពេលដែលការកំណត់ និងតាំងថ្លៃទំនិញ និងសេវាជាប្រាក់រៀលនៅក្នុងសកម្មភាពពាណិជ្ជកម្មមិនមែនមានន័យជាស្វ័យប្រវត្តិថាការទូទាត់ត្រូវតែចាំបាច់ធ្វើឡើងជាប្រាក់រៀលទេ។ កត្តាជាច្រើនដែលមានឥទ្ធិពលទៅលើជម្រើសមធ្យោបាយទូទាត់អាចជាប្រភពចំណូល ភាពងាយស្រួល និងការចំណេញទទួលបានពីការទូទាត់ដូចដែលបានបង្ហាញដោយលទ្ធភាពស្រាវជ្រាវរបស់ AMRO និង JICA។ នៅដំណាក់កាលដំបូងការប្រើប្រាស់ប្រាក់រៀលក្នុងការទូទាត់អាចត្រូវបានលើកទឹកចិត្ត និងពង្រឹង ហើយប្រសិនបើចាំបាច់អាចត្រូវដាក់ឱ្យអនុវត្តចំពោះប្រតិបត្តិការដែលទាក់ទងនឹងវិស័យសាធារណៈ និងចំពោះប្រតិបត្តិការដែលមានតម្លៃតូចៗនៅ

ក្នុងវិស័យឯកជន។ ដូចក្នុងការកំណត់និងតាំងថ្លៃទំនិញជារូបិយវត្ថុដែរវិធានការលើកកម្ពស់ការទូទាត់ជាប្រាក់រៀលនឹងត្រូវធ្វើទៀតជាបណ្តើរៗស្របតាមការវិវត្តនៃសភាពការណ៍ និងទុករយៈពេលអន្តរកាលមួយជូនភ្នាក់ងារសេដ្ឋកិច្ចដើម្បីអនុវត្ត។

ជារួមអំឡុងពេលអន្តរកាលអាចមានរយៈពេលខុសៗគ្នាអាស្រ័យទៅនឹងប្រភេទទំនិញ ឬសេវាកម្ម ឬផ្នែក និងជាកម្មវត្ថុនៃវិធានការណ៍និងជាកិច្ចខិតខំប្រឹងប្រែងសម្រាប់កិច្ចសហប្រតិបត្តិការរវាងមូលដ្ឋានផ្ទាល់។

**៣.៣.៤ គោលនយោបាយអភិវឌ្ឍន៍ទីផ្សារ**

នៅក្នុងពេលកន្លងមកទីផ្សារហិរញ្ញវត្ថុដែលគាំទ្រការប្រើប្រាស់រូបិយវត្ថុជាតិស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ។ ទីផ្សារទាំងនេះនឹងបង្កើនបរិយាកាសអំណោយផលដល់ការប្រើប្រាស់ប្រាក់រៀលនិងឧបករណ៍ហិរញ្ញវត្ថុជារៀល និងផ្តល់ភាពងាយស្រួលដល់គំនិតផ្តួចផ្តើមដទៃទៀតក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល។ ទីផ្សារសំខាន់ៗដែលត្រូវអភិវឌ្ឍរួមមាន៖ ទីផ្សារប្តូរប្រាក់ ទីផ្សារអន្តរធនាគារ និងរូបិយវត្ថុ និងទីផ្សារមូលបត្រ។

**ក. ការអភិវឌ្ឍទីផ្សារប្តូរប្រាក់៖** ទីផ្សារប្តូរប្រាក់ជាសសរទ្រូងមួយដ៏សំខាន់នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុដែលមានតួនាទីដ៏សកម្មក្នុងការជួយសម្រួលការប្រើប្រាស់ប្រាក់រៀល។ នាពេលបច្ចុប្បន្ននេះទីផ្សារប្តូរប្រាក់នៅកម្ពុជាមានលក្ខណៈជាទីផ្សាររាយដែលមានអាជីវករប្តូរប្រាក់ដើរតួនាទីដ៏សំខាន់ ហើយប្រតិបត្តិការទូទាត់នៅពឹងផ្អែកលើការប្រើប្រាស់សាច់ប្រាក់ជាជាងការបង្វែរតាមប្រព័ន្ធធនាគារ ដែលធ្វើឱ្យទីផ្សារនេះមិនទាន់មានភាពស៊ីជម្រៅនៅឡើយ។ នាពេលកន្លងមក ទីផ្សារនេះបានគាំទ្រការប្រើប្រាស់រូបិយប័ណ្ណអន្តរជាតិរបស់ភ្នាក់ងារសេដ្ឋកិច្ចដោយសារវត្តមានស្ទើរគ្រប់ទីកន្លែងនៃអាជីវករប្តូរប្រាក់ ភាពរីកចម្រើននៃបណ្តាញភ្នាក់ងារប្តូរប្រាក់ក្រៅផ្លូវការនៅក្នុងតំបន់ និងថ្នាក់ជាតិការផ្តល់នូវអត្រាប្តូរប្រាក់ក្នុងកម្រិតអំណោយផលដល់អ្នកប្រើប្រាស់រូបិយប័ណ្ណ (បច្ចុប្បន្នគម្លាតអត្រាប្តូរប្រាក់នៅកម្ពុជាមានកម្រិតទាបបើធៀបនឹងប្រទេសដទៃទៀត ហើយមិនទាន់មានការដាក់ពន្ធលើការប្តូរប្រាក់ទេ)។ ការអភិវឌ្ឍទីផ្សារប្តូរប្រាក់បន្ថែមទៀតឱ្យក្លាយជាទីផ្សារលក់ដុំ និងមានគ្រឹះស្ថានធនាគារជាអ្នកដើរតួនាទីស្នូលក្នុងប្រតិបត្តិការប្តូរប្រាក់មានសាសំខាន់ណាស់ដើម្បីប្រមូលរូបិយប័ណ្ណអន្តរជាតិឱ្យចូលទៅក្នុងវិស័យធនាគារ និងឆ្លើយតបទៅនឹងតម្រូវការប្រាក់រៀលនៅលើទីផ្សារឱ្យកាន់តែប្រសើរឡើង។ នៅក្នុងទិសដៅនេះអាជ្ញាធរគួរបង្កើនការត្រួតពិនិត្យពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ និងសមត្ថភាពស្ថាប័នដើម្បីឱ្យទីផ្សារប្តូរប្រាក់ប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមានការគ្រប់គ្រងល្អដែលអំណោយផលដល់ការគៀងគររូបិយប័ណ្ណអន្តរជាតិចូលក្នុងប្រព័ន្ធធនាគារ និងការផ្គត់ផ្គង់ប្រាក់រៀលឱ្យបានកាន់តែច្រើននៅក្នុងសេដ្ឋកិច្ច។

**ខ. ទីផ្សារអន្តរធនាគារ និងរូបិយវត្ថុ ៖** ទីផ្សារអន្តរធនាគារ និងរូបិយវត្ថុនាពេលបច្ចុប្បន្ននេះកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ។ ធនាគារធំៗមួយចំនួនបានបង្កើតទំនាក់ទំនងតាមរយៈការផ្គត់ផ្គង់ឥណទាន និងការដាក់ប្រាក់បញ្ញើ ប៉ុន្តែទំនាក់ទំនងនេះនៅពុំសូវមានលក្ខណៈសកម្មនៅឡើយ។ កន្លងមកធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍទីផ្សារនេះតាមរយៈការបង្កើតមូលបត្រអាចជួញដូរបាន (NCD) ការដាក់ឱ្យដំណើរការនូវប្រតិបត្តិការផ្តល់សន្ទនីយភាពជាប្រាក់រៀលដោយមានការធានា (LPCO) និងការដាក់ឱ្យប្រើប្រាស់ ប្រព័ន្ធអនឡាញត្រេដឹង (online trading plateform) ដើម្បីសម្រួលដល់ការទិញ-លក់ NCDs ក៏ដូចជាការចូលរួមប្រតិបត្តិការ LPCO ។ ទោះជាយ៉ាងណាការអភិវឌ្ឍទីផ្សារអន្តរធនាគារ

និងរូបិយវត្ថុទាមទារការអភិវឌ្ឍបន្តទៀតដើម្បីជំរុញឱ្យមានទីផ្សារបន្ទាប់ (Secondary Market) ជាពិសេសសម្រាប់មូលបត្រអាចជួញដូរបានជារូបិយវត្ថុជាតិ។

ទន្ទឹមនេះ ការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងរូបិយវត្ថុកំពឹងផ្អែកផងដែរទៅលើការអភិវឌ្ឍ ឧបករណ៍បំណុលរយៈពេលខ្លីផ្សេងទៀត ជាពិសេសប័ណ្ណរតនាគារ។ ប័ណ្ណរតនាគារត្រូវបានចេញផ្សាយលើកដំបូងនៅឆ្នាំ២០០៣ និងបញ្ឈប់ទៅវិញនៅឆ្នាំ២០០៦។ ជាមួយគ្នានេះដែររាជរដ្ឋាភិបាលបាន និងកំពុងសិក្សាលើលទ្ធភាពក្នុងការបង្កើតប័ណ្ណរតនាគារជាប្រាក់រៀល ដើម្បីគ្រប់គ្រងលំហូរសាច់ប្រាក់ និងផ្តល់ហិរញ្ញប្បទានដល់ឱនភាពថវិការដ្ឋ។

សរុបមករដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជាគួរអនុវត្តវិធានការអភិវឌ្ឍឧបករណ៍បំណុលជាប្រាក់រៀលឱ្យកាន់តែមានភាពទាក់ទាញដើម្បីផ្តល់ជម្រើសដល់ការរក្សាទុកនូវទ្រព្យសកម្មជារូបិយវត្ថុជាតិឱ្យកាន់តែសម្បូរបែបក្នុងខណៈដែលពេលបច្ចុប្បន្នប្រាក់ដុល្លារ គឺជាជម្រើសចម្បងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងសាធារណជន។

**គ. ទីផ្សារមូលបត្រ ៖** ទីផ្សារមូលបត្រត្រូវបានបង្កើតឡើងកាលពីចុងឆ្នាំ២០១២ កន្លងទៅ ហើយបច្ចុប្បន្នមានមូលបត្រសាជីវកម្មចំនួន ៥ កំពុងត្រូវបានជួញដូរ។ បើទោះបីជាការជួញដូរនៅមានកម្រិតទាបនៅឡើយ ការបង្កើតទផ្សារមូលបត្រគឺជាមូលដ្ឋានដ៏មានសារសំខាន់ក្នុងការអភិវឌ្ឍឧបករណ៍ហិរញ្ញវត្ថុនានាជាប្រាក់រៀល។ ការកំណត់តម្លៃមូលបត្រជាប្រាក់រៀលបានបង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍទីផ្សារមូលបត្រជារូបិយវត្ថុជាតិ។

យោងទៅតាមលក្ខខណ្ឌដែលមានលក្ខណៈអំណោយផលរបស់សេដ្ឋកិច្ចរាជរដ្ឋាភិបាលគួរចេញផ្សាយសញ្ញាប័ណ្ណរដ្ឋចារឹកជារូបិយវត្ថុជាតិដើម្បីផ្តល់ហិរញ្ញប្បទានចំពោះគម្រោងវិនិយោគរយៈពេលវែងរបស់រាជរដ្ឋាភិបាល។ នៅពេលដែលធនធានហិរញ្ញវត្ថុរបស់វិស័យឯកជនកាន់តែមានការកើនឡើងរដ្ឋាភិបាលគួរពិចារណាជាអាទិភាពលើការស្វែងរកកម្ចីមូលនិធិរយៈពេលវែងពីប្រភពទុនក្នុងស្រុក។ ការខ្ចីនេះអាចនឹងរួមចំណែកកាត់បន្ថយសមាមាត្រនៃបំណុលបរទេសនៅក្នុងបំណុលសាធារណៈសរុប និងកាត់បន្ថយហានិភ័យនៃការប្រែប្រួលអត្រាប្តូរប្រាក់ផងដែរ។

### ៣.៣.៥ ការលើកកម្ពស់ការយល់ដឹង និងការចូលរួម

សាធារណជន គឺជាមូលដ្ឋានគន្លឹះនៃយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ដោយសារគោលនយោបាយនេះអាចមានឥទ្ធិពលដល់ផលប្រយោជន៍សេដ្ឋកិច្ចព្រមទាំងទម្លាប់នៃការរស់នៅរបស់ពួកគេ។ តាមរយៈការសិក្សាកន្លងមកបានបង្ហាញថាការប្រើប្រាស់ប្រាក់ដុល្លារ បានចាក់ឫសគល់យ៉ាងជ្រៅក្នុងផ្នត់គំនិតរបស់ប្រជាជន ហើយការប្រើប្រាស់ និងការគិតចំនួនទឹកប្រាក់នានាជាប្រាក់ដុល្លារសម្រាប់ប្រជាជនមួយចំនួនបានក្លាយជាទម្លាប់ទៅហើយ។ ហេតុដូចនេះ ការសម្រេចនូវគោលនយោបាយលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ មិនអាចធ្វើឡើងដោយអត្តនោម័ត និងដោយគ្មានការចូលរួមពីសំណាក់សាធារណជនឡើយ។ នៅក្នុងទិសដៅនេះ សាធារណជនចាំបាច់ត្រូវយល់ដឹងឱ្យកាន់តែច្បាស់ពីអត្ថប្រយោជន៍នៃរូបិយវត្ថុជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងរួមចំណែកនៅក្នុងដំណើរការនៃការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ។ ការបង្ក្រាបនិងលើកទឹកចិត្តឱ្យចូលរួមនេះអាចនឹងធ្វើឡើងតាមរយៈរូបភាពនានាជាពិសេស

ប្រព័ន្ធផ្សព្វផ្សាយនានា ការរៀបចំសិក្ខាសាលា ឬវេទិកាពិភាក្សារវាងអាជ្ញាធរ និងសាធារណជន និងនៅក្នុងប្រព័ន្ធអប់រំជាដើម។

**៣.៣.៦ គោលនយោបាយគាំទ្រនានា**

ដើម្បីរក្សានិរន្តរភាពនៃការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលគោលនយោបាយគាំទ្រនានាគួរតែត្រូវអនុវត្ត។ ជាក់ស្តែងប្រទេសមួយចំនួនដែលខ្វះខាតនូវគោលនយោបាយគាំទ្រទាំងនេះបានជួបប្រទះនឹងការកើនឡើងវិញនូវកម្រិតដុល្លារូបនីយកម្មបន្ទាប់ពីបានកាត់បន្ថយកម្រិតដុល្លារូបនីយកម្មបានមួយរយៈពេល។

គោលនយោបាយគាំទ្រទាំងនេះអាចគ្របដណ្តប់ទៅលើការងារជាច្រើនដូចជា៖

- អាជ្ញាធរគួរបញ្ជាស្មារតីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងរាល់ក្របខ័ណ្ឌច្បាប់ និង បទប្បញ្ញត្តិផ្សេងៗ ដូចជាការប្រើប្រាស់ឯកតារៀលសម្រាប់កំណត់បៀវត្សអប្បបរមាជាដើម។
- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងអំពើពុករលួយ នឹងចូលរួមចំណែកដោយប្រយោលដល់ការពង្រឹងការប្រើប្រាស់រូបិយវត្ថុជាតិ ដោយសារសកម្មភាពទាំងនោះអាចជាបរិយាកាសអំណោយផលដល់ការប្រើប្រាស់រូបិយប័ណ្ណអន្តរជាតិ។
- ប្រែក្លាយពីវិស័យក្រៅផ្លូវការទៅជាវិស័យផ្លូវការជាលំដាប់ដូចជា ការចុះបញ្ជីក្រុមហ៊ុន និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាដើម ដើម្បីឱ្យសកម្មភាពសេដ្ឋកិច្ចទាំងនេះអាចទទួលផលកាន់តែច្រើនពីការប្រើប្រាស់ប្រាក់រៀលក៏ដូចជាជំរុញតម្រូវការប្រាក់រៀល ដូចជាការអាចទទួលបានឥណទានជាប្រាក់រៀលក្នុងអត្រាសមរម្យ និងការប្រើប្រាស់សេវាកម្មទូទាត់ជាប្រាក់រៀល ។
- វិនិយោគិននិងសហគ្រិននានាគួរត្រូវបានលើកទឹកចិត្តឱ្យធ្វើប្រតិបត្តិការរបស់ខ្លួនជាប្រាក់រៀលជាលំដាប់ក្នុងកំឡុងពេលបាននិងកំពុងដំណើរការអាជីវកម្មរបស់ខ្លួននិងជាពិសេសនៅមុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការអាជីវកម្ម។
- គួរមានការសិក្សាបង្កើតគម្រោងសន្សំខ្នាតតូចៗជាប្រាក់រៀល។ គម្រោងនេះអាចផ្តួចផ្តើមដោយកិច្ចសហការរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានាហើយបន្ទាប់មកឱ្យវិស័យឯកជនចូលរួមដើម្បីរក្សានិរន្តរភាពនៃគម្រោង។ គម្រោងនេះគួរពង្រីកជាលំដាប់នៅទូទាំងប្រទេស។
- នៅក្នុងរយៈពេលមធ្យមនិងវែងការសិក្សាលើការដាក់គំហិតលើការកាន់កាប់រូបិយប័ណ្ណនៅក្នុងប្រតិបត្តិការដោយភ្នាក់ងារដែលមិនមានប្រតិបត្តិការជាមួយភ្នាក់ងារនៅក្រៅប្រទេសនឹងត្រូវចាប់ផ្តើមនិងត្រូវធានាឱ្យបានថាវិធានការនេះនឹងមិនប៉ះពាល់ដល់លំហូរចេញនៃមូលធនទេ។
- ផ្តល់ការលើកទឹកចិត្តចំពោះគ្រឹះស្ថានធនាគារនិងក្រុមហ៊ុននានា ក្នុងការបើកគណនីជាប្រាក់រៀលជូននិយោជិក។ ការងារនេះទាមទារឱ្យមានកិច្ចសហការរវាងរាជរដ្ឋាភិបាល ក៏ដូចជាធនាគារជាតិនៃកម្ពុជាដើម្បីឱ្យនិយោជិកអាចប្រើប្រាស់សេវាធនាគារក្នុងប្រតិបត្តិការសេដ្ឋកិច្ចនានា និងបន្ថយសាច់ប្រាក់ដែលបច្ចុប្បន្នអាចមានចំនួនច្រើនចំពោះការទូទាត់ប្រាក់ធំៗ។

# ជំពូកទី៤

# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤

# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

- គោលនយោបាយអត្រាប្តូរប្រាក់ ប្រាក់បម្រុងកាតព្វកិច្ច និងការគ្រប់គ្រងការផ្គត់ផ្គង់សាច់ប្រាក់របស់ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុឱ្យមានស្ថិរភាព បង្កើនទំនុកចិត្តរបស់អ្នកវិនិយោគ និងអ្នកប្រើប្រាស់ក្នុងស្រុក។ វាក៏ជាឧបករណ៍ជួយទប់ស្កាត់ការកើនឡើងនៃអត្រាឡើងថ្លៃ និងការបាត់បង់តម្លៃប្រាក់។
- ការដឹកនាំផ្លូវការទៅរកការប្រើប្រាស់ប្រាក់រៀល និងការកាត់បន្ថយចំណាយប្រតិបត្តិការរដ្ឋ មានឥទ្ធិពលវិជ្ជមានលើការបង្កើតបរិយាកាសដើម្បីទាក់ទាញវិនិយោគ និងជម្រុញការផ្តល់ការងារ។ វាធ្វើឱ្យសេដ្ឋកិច្ចក្នុងស្រុកកាន់តែសកម្ម និងចល័ត។
- ការប្រើប្រាស់ប្រាក់រូបិយវត្ថុជាតិ ជាឧបករណ៍ជំនួញធ្វើឱ្យប្រជាជនមានអារម្មណ៍ថាជាអ្នកកាន់កាប់អំណាចសេដ្ឋកិច្ច និងមានសិទ្ធិពេញលេញលើបច្ចេកវិជ្ជានៃការរីកចម្រើនជាតិ។ វាជារូបសញ្ញានៃឯករាជ្យភាព និងភាពសាមគ្គីជាតិ។
- ប្រសិនបើប្រជាជនប្រើប្រាស់ប្រាក់រៀលកាន់តែទូលំទូលាយ នោះនឹងជួយឱ្យរដ្ឋអាចតាមដានចំណូលចំណាយបានកាន់តែមានប្រសិទ្ធភាព។ វាជាឧបករណ៍ដ៏សំខាន់សម្រាប់ការរៀបចំផែនការអភិវឌ្ឍប្រទេសឱ្យសមស្របនឹងបំណងជាតិ។
- ធនាគារជាតិនៃកម្ពុជាបានអនុវត្តគោលនយោបាយរូបិយវត្ថុដែលមានលក្ខណៈទន់ភ្លន់ដែលរួមមានការរក្សាស្ថិរភាពអត្រាការប្រាក់ និងអត្រាប្តូរប្រាក់មិនឱ្យមានការប្រែប្រួលខ្លាំងព្រមជាមួយនឹងការកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ចរបស់ធនាគារពាណិជ្ជជាប្រាក់រៀលទាបជាងរូបិយប័ណ្ណបរទេស ដែលជំរុញឱ្យស្ថាប័នធនាគារពាណិជ្ជខិតខំបង្កើននូវប្រតិបត្តិការសេវាកម្មរបស់ខ្លួនជារូបិយវត្ថុជាតិ។
- ការប្រើប្រាស់ប្រាក់រៀល បានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជា អនុវត្តគោលនយោបាយរូបិយវត្ថុរបស់ខ្លួនបានប្រសើរជាងមុន បរិមាណតម្រូវការប្រាក់រៀលនៅក្នុងប្រព័ន្ធធនាគារ។ ដោយសារការកើនឡើងនៃបរិមាណតម្រូវការប្រាក់រៀលនៅក្នុងប្រព័ន្ធធនាគារ។
- ធនាគារជាតិនៃកម្ពុជា គឺជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា។
- បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយពិគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។
- ធនាគារជាតិនៃកម្ពុជាមានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយប្រាក់រៀលដែលជារូបិយវត្ថុជាតិ។
- ធនាគារជាតិនៃកម្ពុជា ជាអ្នកផ្តល់និងដកហូតអាជ្ញាប័ណ្ណចេញបទប្បញ្ញត្តិនិងត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា។ លើសពីនេះទៀតធនាគារជាតិនៃកម្ពុជាធ្វើការវិភាគស្ថានភាព

សេដ្ឋកិច្ចនិងរូបិយវត្ថុជាប្រចាំចេញផ្សាយរបាយការណ៍ និងព្រឹត្តិបត្រផ្សេងៗត្រួតពិនិត្យប្រព័ន្ធទូទាត់ជាតិដំឡើងតារាងស្ថិតិជញ្ជីងទូទាត់ និងចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យក្រៅប្រទេស។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ក្រៅពីចំណុចខ្លាំងខាងក្រោមនេះគឺជាចំណុចខ្សោយមួយចំនួនរបស់ប្រធានបទ៖

- ទោះមានការខិតខំជំរុញការប្រើប្រាស់ប្រាក់រៀល ប៉ុន្តែប្រជាជនភាគច្រើននៅតែចូលចិត្តការប្រើប្រាស់ដុល្លារ ដោយសារប្រវត្តិនៃការថយចុះតម្លៃប្រាក់រៀលនៅក្នុងអតីតកាល។ ការខ្វះជំនឿនេះប៉ះពាល់ដល់គោលនយោបាយលើការប្រើប្រាស់ប្រាក់ជាតិ។
- ប្រព័ន្ធគ្រប់គ្រងដូចជា ប្រាក់បម្រុងការគ្រប់គ្រងអត្រាប្តូរប្រាក់ និងការបង្ការក្លែងក្រដាសប្រាក់ត្រូវការមធ្យោបាយទំនើបៗជាចាំបាច់។ បើគ្មានការវិនិយោគលើបច្ចេកវិទ្យា និងបុគ្គលិកមានជំនាញគោលនយោបាយនឹងជួបបញ្ហាក្នុងការអនុវត្ត។
- គោលនយោបាយហិរញ្ញវត្ថុមិនអាចអនុវត្តដោយធនាគារជាតិតែមួយបានទេ ត្រូវការសហការជាប្រព័ន្ធជាមួយក្រសួងសារពើពន្ធ ក្រសួងពាណិជ្ជកម្ម និងធនាគារឯកជន។ ប្រសិនបើការសម្របសម្រួលមិនរលូនអាចនាំទៅរកការខកខាន និងភាពអាចបណ្តាលឱ្យប្រសិទ្ធភាពនៃគោលនយោបាយថយចុះ។
- ការបង្ហាញឥទ្ធិពលនៃគោលនយោបាយលើប្រាក់រៀលមិនអាចរួមចំណែកដោយរដ្ឋប៉ុណ្ណោះបានទេត្រូវការការចូលរួមពីសាធារណជន សហគ្រាសឯកជន និងវិស័យធនាគារ។ បើគ្មានការចូលរួមទូលំទូលាយនឹងធ្វើឱ្យគោលនយោបាយអនិច្ចងាយរងការបរាជ័យ។
- ការប្រើប្រាស់ប្រាក់រៀល មិនទាន់សូវមានការចរាចរណ៍នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចបានទូលំទូលាយនៅឡើយដែលជាបញ្ហារាំងស្ទះមិនអាចឱ្យការអនុវត្តយុទ្ធសាស្ត្រនៃការប្រើប្រាក់រៀលដើម្បីឱ្យមានប្រសិទ្ធភាពខ្ពស់។
- ការជឿជាក់លើប្រាក់រៀលនៅតិចព្រោះប្រជាជនមួយចំនួននៅតែគាំទ្រប្រាក់បរទេស ជាពិសេសមិនថាម្ចាស់សហគ្រាស ឬវិនិយោគិនសុទ្ធសឹងតែត្រូវការប្រើប្រាស់ប្រាក់បរទេសក្នុងការធ្វើជំនួញរបស់ពួកគាត់។
- ការប្រើប្រាស់ប្រាក់បរទេសកាន់តែខ្ពស់ ដែលនាំឱ្យមានហានិភ័យនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ ប្រសិនបើអាជ្ញាធរគ្រប់គ្រងមិនបានល្អ។
- ការប្រើប្រាស់រូបិយវត្ថុជាតិនៅតែជួបបញ្ហាអត្រាប្តូរប្រាក់មិនថេរបើប្រៀបធៀបជាមួយរូបិយប័ណ្ណបរទេស។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

## ៥.១ សេចក្ដីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវកន្លងមកនេះ ក្រុមនាងខ្ញុំសូមធ្វើការសន្និដ្ឋានអំពីប្រធានបទខាងលើបានបង្ហាញយ៉ាងច្បាស់ថា ប្រាក់រៀលមិនត្រឹមតែជារូបិយវត្ថុប្រើប្រាស់សម្រាប់ការទូទាត់ប្រចាំថ្ងៃនោះទេ ប៉ុន្តែមានតួនាទីសំខាន់បំផុតសម្រាប់ជំរុញសេដ្ឋកិច្ចជាតិ ទប់ស្កាត់ការពឹងផ្អែកលើរូបិយប័ណ្ណបរទេស និងជួយបង្កើនផ្នែកហិរញ្ញវត្ថុ។ ក្នុងនាមជារូបិយវត្ថុជាតិ ប្រាក់រៀលមានន័យជាអត្តសញ្ញាណជាតិ ដែលបង្ហាញពីប្រព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសជាតិ មិនត្រឹមតែជារូបិយវត្ថុដែលមានតម្លៃចំណេញក្នុងពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែជាកត្តាសង្គមវប្បធម៌ដែលជួយបង្កើតអារម្មណ៍ស្មោះត្រង់ និងសាមគ្គីភាពរវាងប្រជាពលរដ្ឋនៃជាតិ។

ការប្រើប្រាស់ប្រាក់រៀលជាប្រចាំមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការរក្សាស្ថិរភាពសេដ្ឋកិច្ចដោយជួយកាត់បន្ថយហានិភ័យប៉ះពាល់អាក្រក់ពីការប្រែប្រួលអត្រាប្តូរប្រាក់នៅលើទីផ្សារអន្តរជាតិ ដែលជារឿងមួយដែលប្រទេសកម្ពុជា ប្រឈមមុខជាញឹកញាប់ដោយសារតែការពឹងផ្អែកខ្លាំងលើប្រាក់ដុល្លារអាមេរិកក្នុងប្រព័ន្ធហិរញ្ញវត្ថុ។ ឧបករណ៍គ្រប់គ្រងនយោបាយប្រាក់រៀលរបស់ធនាគារជាតិអាចអនុវត្តបានយ៉ាងមានប្រសិទ្ធភាព ប្រសិនបើប្រជាជនយល់ឃើញពីតម្លៃ និងសារសំខាន់នៃការប្រើប្រាស់ប្រាក់រៀល និងធ្វើការចូលរួមក្នុងការជម្រុញការប្រើប្រាស់នោះ។ ការគ្រប់គ្រងសាច់ប្រាក់ ការកំណត់អត្រាប្តូរប្រាក់ និងគោលនយោបាយសារពើពន្ធ នឹងអាចដំណើរការបានយ៉ាងត្រឹមត្រូវនៅពេលដែលប្រព័ន្ធប្រាក់ជាតិមានអំណាចពេញលេញក្នុងប្រទេស។

ម្យ៉ាងទៀតការប្រើប្រាស់ប្រាក់រៀលជាឧបករណ៍ផ្លូវការមានអត្ថប្រយោជន៍ក្នុងការពង្រឹងប្រព័ន្ធធនាគារជាតិដោយវាផ្តល់ឱកាសឱ្យធនាគារជាតិនៃកម្ពុជា អនុវត្តន៍គោលនយោបាយសេដ្ឋកិច្ចប្រាក់ និងអាចត្រួតពិនិត្យលំហូរហិរញ្ញវត្ថុបានយ៉ាងត្រឹមត្រូវ។ វាផ្តល់ឱកាសដល់ការអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុក្នុងស្រុកដូចជាការបង្កើតមជ្ឈមណ្ឌលផ្លាស់ប្តូរប្រាក់ដែលផ្អែកលើរៀល ការជម្រុញឱ្យមានប្រព័ន្ធទូទាត់អេឡិចត្រូនិចប្រើប្រាស់ប្រាក់រៀល និងការលើកកម្ពស់បរិយាកាសវិនិយោគក្នុងស្រុក។ លើសពីនេះការប្រើប្រាស់ប្រាក់រៀលក៏ជួយបង្កើនប្រាក់ចំណូលសរុបរបស់រដ្ឋតាមរយៈការបង់ពន្ធឱ្យបានច្បាស់លាស់ពង្រឹងការត្រួតពិនិត្យ និងការរៀបចំគណនេយ្យរដ្ឋឱ្យបានត្រឹមត្រូវ។

បន្ថែមពីនេះទៅទៀត ការប្រើប្រាស់ប្រាក់រៀលមានឥទ្ធិពលអវិជ្ជមានទៅលើការក្លែងបន្លំក្រដាសប្រាក់ និងការរកកម្រៃក្រៅប្រព័ន្ធផ្លូវការដោយខុសច្បាប់ ព្រោះការប្រើប្រាស់រូបិយវត្ថុជាតិអាចត្រូវបានតាមដាន និងគ្រប់គ្រងបានយ៉ាងប្រសើរ។ វាជាជំហានសំខាន់មួយក្នុងការកែលម្អភាពតម្លាភាពហិរញ្ញវត្ថុ និងជួយដល់ការបង្កើតភាពជឿជាក់ពីសំណាក់អ្នកវិនិយោគទាំងក្នុងស្រុក និងអន្តរជាតិ។ ជាក់ស្តែងការអភិវឌ្ឍន៍នយោបាយសេដ្ឋកិច្ចណាមួយ ដែលមិនមានស្ថិរភាពរូបិយវត្ថុជាតិ គឺជាបញ្ហាដ៏ធំមួយដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ជារឿយៗដល់វិស័យសេដ្ឋកិច្ចទាំងមូល។

ក្នុងចំណោមមូលហេតុទាំងនេះបញ្ជាក់យ៉ាងច្បាស់ថា ការជម្រុញឱ្យប្រជាពលរដ្ឋប្រើប្រាស់ប្រាក់រៀល ជាឧបករណ៍ប្រចាំថ្ងៃ ដោយការបង្កើនការយល់ដឹង ការអប់រំហិរញ្ញវត្ថុ និងការចូលរួមរបស់សហគមន៍ គឺជាចំណុចគន្លឹះសម្រាប់ការកសាងសេដ្ឋកិច្ចជាតិឱ្យរឹងមាំ និងចីរភាព។ រដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធគួរតែបន្តអនុវត្តយុទ្ធសាស្ត្រជាក់លាក់ដូចជា ការលើកកម្ពស់ការប្រើប្រាស់សេវាហិរញ្ញវត្ថុជាស្ថាពរ(digital riel, QR code, KHQR) ការផ្តល់លទ្ធភាពឱ្យមានការប្តូរប្រាក់សាមញ្ញ និងការឧបត្ថម្ភពីភាគីពាក់ព័ន្ធទាំងអស់ក្នុងការចូលរួមជាឯកភាពក្នុងយុទ្ធនាការនេះ។

ដូចនេះសេចក្តីសន្និដ្ឋានបង្ហាញយ៉ាងច្បាស់ថាប្រាក់រៀលគឺជាគ្រឿងចម្បងសម្រាប់ការជំរុញសេដ្ឋកិច្ចជាតិ និងជាគ្រឹះសម្រាប់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុឱ្យបាន សុវត្ថិភាព និងមានភាពប្រសើរឡើងប្រកបដោយស្ថិរភាពរយៈពេលវែង។ ការចងភ្ជាប់រវាងអត្តសញ្ញាណជាតិ ការអភិវឌ្ឍសេដ្ឋកិច្ច និងឯករាជ្យរូបិយវត្ថុគឺជាចំណុចដ៏សំខាន់ដែលគ្រប់សង្គមគួរយល់ដឹង និងបន្តការប្តេជ្ញាចិត្តសម្រេចអនាគតសេដ្ឋកិច្ចខ្មែរ តាមរយៈការជឿជាក់ និងប្រើប្រាស់ប្រាក់រៀលជាប្រចាំ។

## ៥.២ ការផ្តល់អនុសាសន៍

ក្រុមនាងខ្ញុំសូមធ្វើការផ្តល់ជាគំនិត និងអនុសាសន៍មួយចំនួនក្នុងន័យចូលរួមកែលម្អ និងផ្តល់ជាទស្សនទានសម្រាប់អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែមានភាពប្រសើរឡើង។ ក្រុមនាងខ្ញុំសូមផ្តល់ជាអនុសាសន៍ដូចខាងក្រោមនេះ៖

- ត្រូវពង្រឹងស្ថិរភាពរូបិយវត្ថុ និងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ដើម្បីបំបាត់ការស្ទាក់ស្ទើរនៃប្រជាជនដែលខ្លាចថាប្រាក់រៀលនឹងថយតម្លៃ ដូចជាបទពិសោធន៍នៅអតីតកាល។ យុទ្ធសាស្ត្រផ្សព្វផ្សាយផ្នែកហិរញ្ញវត្ថុគួរត្រូវបានអនុវត្តយ៉ាងទូលំទូលាយ និងទាន់សម័យ ដើម្បីបង្កើនការយល់ដឹង និងជំនឿរបស់សាធារណជន។
- ប្រាក់បម្រុង ការគ្រប់គ្រងអត្រាប្តូរប្រាក់ និងការការពារក្លែងក្រដាសប្រាក់ គឺជាគ្រឿងចក្រសំខាន់។ ដូច្នេះត្រូវពង្រឹងកម្រិតវិនិយោគលើបច្ចេកវិទ្យា និងអភិវឌ្ឍសមត្ថភាពបុគ្គលិកដើម្បីធានាបាននូវប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងការអនុវត្តគោលនយោបាយរូបិយវត្ថុ។
- គោលនយោបាយហិរញ្ញវត្ថុមិនអាចអនុវត្តដោយស្ថាប័នតែមួយបានទេ។ ដូច្នេះត្រូវចាំបាច់មានការសហការយ៉ាងរឹងមាំ និងច្បាស់លាស់ជាប្រព័ន្ធរវាងធនាគារជាតិ ក្រសួងសារពើពន្ធ ក្រសួងពាណិជ្ជកម្ម និងស្ថាប័នឯកជន ដើម្បីចៀសវាងភាពខកខាន និងបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តន៍គោលនយោបាយ។
- រដ្ឋមិនអាចទទួលខុសត្រូវពេញលេញលើការបង្ហាញឥទ្ធិពលនៃគោលនយោបាយប្រាក់រៀលបានទេ។ ដូច្នេះត្រូវលើកទឹកចិត្តឱ្យសហគ្រាសឯកជនធនាគារ និងប្រជាជនទូទៅចូលរួមជាសកម្មក្នុងការប្រើប្រាស់ប្រាក់រៀល ដោយផ្តល់សាច់ដុំគាំទ្រដែលអាចជំរុញការផ្លាស់ប្តូរ។
- ត្រូវដាក់វិធានការណ៍ជាក់លាក់ ដើម្បីជម្រុញឱ្យប្រាក់រៀលមានចលនាធំទូលាយក្នុងប្រព័ន្ធសេដ្ឋកិច្ចដូចជា៖ ការទូទាត់ប្រាក់ឈ្នួលរដ្ឋឱ្យជាប្រាក់រៀលការបង់ពន្ធ និងសេវាសាធារណៈផ្សេងៗត្រូវប្រើប្រាស់ប្រាក់រៀលជាចម្បង។

- ត្រូវបង្កើនការយល់ដឹងពីតម្លៃនៃប្រាក់រៀល និងបង្កើតអរិយធម៌បរិច្ឆេទរូបិយវត្ថុជាតិ។ វិនិយោគិន និង ម្ចាស់សហគ្រាសគួរតែត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ប្រាក់រៀលក្នុងកិច្ចប្រតិបត្តិការជំនួញនានា ដោយបង្កើតអត្ថប្រយោជន៍ផ្នែកសារពើពន្ធ ឬគោលនយោបាយលើកទឹកចិត្តផ្សេងៗ។
- ត្រូវមានការត្រួតពិនិត្យប្រកបដោយច្បាប់ និងច្បាស់លាស់លើការប្រើប្រាស់រូបិយវត្ថុបរទេសដើម្បីទប់ ស្កាត់ហានិភ័យដល់សេដ្ឋកិច្ចជាតិ និងបង្កើនទំនួលខុសត្រូវក្នុងប្រព័ន្ធហិរញ្ញវត្ថុ។
- ដើម្បីបង្កើនការជឿជាក់សម្រាប់អ្នកប្រើប្រាស់ត្រូវពង្រឹងកំណត់អត្រាប្តូរប្រាក់ឱ្យមានភាពស្ថិរភាព និងទាន់ពេលវេលាដោយផ្អែកលើព័ត៌មានទីផ្សារពិតប្រាកដនិងប្រើប្រព័ន្ធបច្ចេកវិទ្យាដើម្បីបង្កើនភាព អាចពិភាក្សានិងការចូលដំណើរការព័ត៌មានសាធារណៈ។

# ឯកសារយោង


## ឯកសារជាខេមរភាសា

1. ធនាគារជាតិនៃកម្ពុជា. *“សារៈសំខាន់នៃការប្រើប្រាស់ប្រាក់រៀលសម្រាប់កម្ពុជា”* Retrieved June, 12 2025 from https://www.nbc.gov.kh/download_files/booklet/Riel-Booklet-Khmer.pdf
2. ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល - RULE E-Library
3. សកលវិទ្យាល័យជាតិគ្រប់គ្រង. ស៊ុំ សុចិន្តា. *“ប្រវត្តិគំនិតសេដ្ឋកិច្ច(សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន)”*
4. វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០២៤). *“រូបិយវត្ថុ និងធនាគារ(ភាគទី១)”* បោះពុម្ពលើកទី៦. ទំព័រទី២ ភ្នំពេញ
5. វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០១៩). *“សេចក្តីផ្តើមនៃនីតិ”* បោះពុម្ពលើកទី៨. ទំព័រទី៣. ១១០ទំព័រ. ភ្នំពេញ
6. វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០១២). *“មីក្រូសេដ្ឋកិច្ចវិទ្យា”* បោះពុម្ពលើកទី៣. ទំព័រទី៤. ១២០ទំព័រ. ភ្នំពេញ
7. វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត

## ឯកសារពីគេហទំព័រ

8. KHsearch. សេដ្ឋកិច្ច. (2020, January 05). *និយមន័យរូបិយវត្ថុ*. Retrieved from *https://www.khsearch.com/qna/27205*
9. KHINFO. (2021, December 16). *និយមន័យនីតិ*. Retrieved from *https://www.facebook.com*
10. KHsearch. Chanheng Menh. (2021, March 04). *តើសេដ្ឋកិច្ចជាអ្វី.* Retrieved from https://www.khsearch.com/qna/13654
11. KHsearch. ទីផ្សារ. (2019, July 9). *អ្វីទៅជានិយមន័យសេដ្ឋកិច្ច.* Retrieved from https://www.khsearch.com/qna/22672

# ឧបសម្ព័ន្ធ

## រូបិយវត្ថុស្ថិតក្នុងចរាចរណ៍លើទីផ្សារ



# រូបិយវត្ថុចាស់



# រូបិយវត្ថុឥណ្ឌូចិន




10
DIX PIASTRES


10
DIX PIASTRES


10
DIX PIASTRES

10
VIỆN PHÁT HÀNH
10

100
100
CENT PIASTRES


100
100
CENT PIASTRES


100
100
CENT PIASTRES

100
VIỆN PHÁT HÀNH
100

200
DEUX CENTS PIASTRES
200


200
200

200
DEUX CENTS PIASTRES
200